**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University Of Law And Economics

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ លោក **រ៉យ សុភ័ក្រ**

លោក **ម៉ៅ វ៉ាន់ឈិញ**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **សុខ ចិន្តា**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលរៀន ២០២០

ជំនាន់ទី ២៤

ឆ្នាំសរសេរសារណា ២០២៤

# សេចក្ដីថ្លែងអំណរគុណ

ជាបឋមក្រុមខ្ញុំបាទឈ្មោះ **រ៉យ សុភ័ក្រ** និង **ម៉ៅ វ៉ាន់ឈិញ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០ ដល់ ២០២៤។

ខ្ញុំបាទទាំងពីររូបមានសេចក្ដីសោមនស្ស សូមលំឱនកាយសម្ដែងនូវការគោរពប្រតិបត្តិ និងកតញ្ញូតាធម៌ ចំពោះលោកឪពុក **រ៉យ ឈុនលី** អ្នកម្ដាយ **ឈុន ណារី** និង លោកឪពុក **ម៉ៅ ចំណាន** អ្នកម្ដាយ **ស៊ន់ ស្រីទូច** ដែលបានផ្ដល់កំណើតដល់កូនៗ និងជាមនុស្សដែលរកអ្នកណាមកប្រៀបផ្ទឹមពុំបាន។

លោកទាំងទ្វេរបានខិតខំពុះពាររាល់គ្រប់ឧបសគ្គ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅនិងផ្ដល់នូវដំបូន្មានល្អៗ ក៏ដូចជាជួយជំរុញលើកទឹកចិត្តកូនៗគ្រប់កាលៈទេសៈ ផ្ដល់នូវភាពកក់ក្ដៅ សេចក្ដីស្រលាញ់ ការអនុគ្រោះ ព្រហ្មវិហារធម៌ អប់រំកូនៗឱ្យប្រព្រឹត្តខ្លួន ដើរតាមគន្លងធម៌ឱ្យក្លាយជាកូនល្អ ពលរដ្ឋល្អ នៅក្នុងសង្គមព្រមទាំងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងផ្នែកសម្ភារៈ និងស្មារតីព្រមទាំងផ្ដល់នូវចំណេះដឹងចំពោះកូនៗ តាមរយៈការបញ្ជូនកូនៗ ទៅសិក្សានៅសាលារៀនតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះដោយភាពរលូន និងទទួលបាននូវភាពជោគជ័យ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រីសាស្ត្រាចារ្យ សាស្ត្រាចារ្យជំនួយទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្រួល និងរៀបចំកម្មវិធីសិក្សាសម្រាប់សិស្សនិស្សិតគ្រប់ជាន់ថ្នាក់ ក្នុងការគាំទ្រនៃការសិក្សារបស់យើងខ្ញុំប្រកបដោយភាពរលូន និងភាពជឿទុកចិត្ត។ ជាពិសេសនោះគឺ សិស្សនិស្សិតទទួលបាននូវចំណេះដឹងជាច្រើនតាមរយៈកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ ហើយក៏ជាឆ្អឹងមួយសម្រាប់អភិវឌ្ឍប្រទេសជាតិនាពេលអនាគតផងដែរ។

ចំពោះលោកស្រីសាស្ត្រាចារ្យជំនួយ **សុខ ចិន្ដា** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់យ៉ាងមោះមុត និងចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការផ្ដល់នូវចំណេះដឹងល្អៗដល់ក្រុមខ្ញុំបាទទាក់ទងទៅនឹងប្រធានបទ ស្ដីពី ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការកែតម្រូវនូវកំហុសឆ្គងទាំងឡាយណាដែលមានភាពមិនប្រក្រតីចំពោះការសរសេរសារណារបស់ក្រុមខ្ញុំតាំងពីចាប់ផ្ដើមដំបូងរហូតទទួលបាននូវសមិទ្ធផលដ៏ល្អមួយនេះ។

ជាចុងក្រោយ ក្រុមយើងខ្ញុំទាំងពីរនាក់ សូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅនូវគុណូបការៈរបស់អ្នកមានគុណទាំងទ្វេ និងលោកស្រីសាស្ត្រាចារ្យជាទីគោរព។ កូនសូមលើកដៃទាំងគូរឡើងដើម្បីបួងសួងដល់វត្ថុសក្ដិសិទ្ធិទាំងអស់នៅក្នុងលោកយើងនេះ សូមតាមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តជំនាន់ទី២៤ អស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សម្រាប់ឆ្នាំសិក្សា ២០២០ ដល់ ២០២៤ រួចមកដោយការខិតខំសិក្សារៀនសូត្រ និងការផ្តល់ដំបូន្មានពីសំណាក់លោក លោកស្រីសាស្រ្តាចារ្យ នៅក្នុងសាកលវិទ្យាល័យ បានធ្វើឱ្យយើងខ្ញុំទាំងពីររូបទទួលបានឱកាស ក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទមួយស្តីអំពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

ចំពោះការលើកយក ការទទួលខុសត្រូវព្រហ្មទណ្ឌនេះ មកធ្វើជាប្រធានបទនៃការសរសេរសារណាបញ្ចប់ការសិក្សា គឺមិនមែនជារឿងចៃដន្យនោះទេ ដោយហេតុថាប្រធានបទនេះ គឺមានសារៈសំខាន់ណាស់នៅក្នុងការអនុវត្តផ្ទាល់ ដែលជាផ្នែកមួយនៃការធានាបាននូវភាពយុត្តិធម៌ ក៏ដូចជាគោរពនូវសិទ្ធិនៃការការពារខ្លួនជាដើម។

ក្រុមយើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយណាស់ ដែលមានឱកាសក្នុងការស្រាវជ្រាវ សរសេរ និងរៀបចំសារណាបញ្ចប់ការសិក្សា ក្រោមប្រធានបទមួយស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងមានការណែនាំពីលោកស្រីសាស្រ្តាចារ្យ សុខ ចិន្តា ដែលជាសាស្រ្តាចារ្យមានបទពិសោធន៍ផ្ទាល់ក្នុងសង្គម និងបានចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការចែករំលែកបទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់ក្រុមយើងខ្ញុំ។ សារណាមួយនេះស្រាវជ្រាវ ប្រមូលផ្តុំ និងចងក្រងឡើង ក្នុងគោលបំណងទុកជាឯកសារ សម្រាប់បំពេញនូវតម្រូវការរបស់សិស្សនិស្សិតជំនាន់ក្រោយៗអាចយកទៅសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីបង្កើននូវចំណេះដឹង ក៏ដូចជាយល់ដឹងអំពីច្បាប់ឱ្យកាន់តែទូលំទូលាយទាក់ទងទៅនឹងប្រធានបទមួយនេះ។ ជាពិសេសទៅទៀត មូលហេតុដែលក្រុមយើងខ្ញុំលើកប្រធានបទនេះមកធ្វើជាសារណាបញ្ចប់ការសិក្សា គឺដោយសារក្រុមយើងខ្ញុំបាទចង់សិក្សាស្វែងយល់ឱ្យកាន់តែស៊ីជម្រៅចំពោះរឿងក្តីព្រហ្មទណ្ឌ ជាក់ស្តែងទាក់ទងទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌនេះតែម្តង។

ជាចុងក្រោយ ក្រុមយើងខ្ញុំទាំងពីរនាក់សង្ឃឹមថាសារណាបញ្ចប់ការសិក្សាមួយនេះ ដែលរួមមានការលើកឡើងអំពីទ្រឹស្តីគតិយុត្ត ព្រមទាំងរួមបញ្ចូលជាមួយការអនុវត្តជាក់ស្តែងមួយចំនួនផងដែរ និងអាចធ្វើជាឯកសារជំនួយក្នុងការសិក្សាស្រាវជ្រាវ។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំទាំងពីរសូមធ្វើការអធ្យាស្រ័យទុកជាមុនចំពោះចំណុចខ្វះខាត កំហុសខុសឆ្គង ទាំងខ្លឹមសារ ឃ្លាប្រយោគ ព្រមទាំងអក្ខរាវិរុទ្ធ ដោយអចេតនាដោយប្រការណាមួយ។ ក្រុមយើងខ្ញុំទាំងពីររូប នឹងរង់ចាំទទួលការរិះគន់ និងការកែតម្រូវដើម្បីស្ថាបនាគ្រប់បែបយ៉ាងពីសំណាក់លោក លោកស្រី សាស្រ្តាចារ្យ សិស្សនិស្សិត មិត្តអ្នកអាន និងអ្នកស្តាប់ ដើម្បីឱ្យសារណាមួយនេះកាន់តែមានគុណភាពល្អប្រសើរឡើង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ............ ១
១.លំនាំនៃការស្រាវជ្រាវ ............ ១
២. ចំណោទបញ្ហា ............ ១
៣. គោលបំណងនៃការស្រាវជ្រាវ ............ ២
៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ............ ២
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ២
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ២

**ជំពូកទី១**

**សញ្ញាណគតិយុត្តនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**

**១.១. អត្ថន័យការទទួលខុសត្រូវព្រហ្មទណ្ឌ** ............ ៤
**១.២. គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ** ............ ៤
១.២.១. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ............ ៤
១.២.២. គោលការណ៍ឯកត្តកម្មនៃទោស ............ ៤
**១.៣. ចំណាត់ថ្នាក់នៃបទល្មើស** ............ ៦
១.៣.១. បទលហុ ............ ៦
១.៣.២. បទមជ្ឈិម ............ ៧
១.៣.៣. បទឧក្រិដ្ឋ ............ ៨
**១.៤. ផលប្រយោជន៍នៃការបែងចែកបទល្មើស** ............ ៩
**១.៤.១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល** ............ ៩
១.៤.១.១. អាជ្ញាយុកាលនៃបទល្មើស ............ ៩
១.៤.១.២. អាជ្ញាយុកាលនៃទោស ............ ៩
**១.៤.២. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី** ............ ១០

## ជំពូកទី២
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

**២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន** ........ ១២
**២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌអនីតិជន** ........ ១២
២.២.១. អនីតិជនអាយុក្រោម១៤ឆ្នាំ ........ ១៣
២.២.២. អនីតិជនអាយុចាប់ពី១៤ឆ្នាំទៅដល់ក្រោម១៨ឆ្នាំ ........ ១៣
**២.៣. លក្ខខណ្ឌទាក់ទងបុគ្គលដែលបានចូលរួម** ........ ១៤
២.៣.១. ចារី ........ ១៤
២.៣.២. សហចារី ........ ១៤
២.៣.៣. ការចូលរួមប្រព្រឹត្តបទល្មើសដោយប្រយោល ........ ១៥
២.៣.៣.១. អ្នកផ្ដើមគំនិត ........ ១៥
២.៣.៣.២. អ្នកសមគំនិត ........ ១៥
**២.៤. ទោសដែលត្រូវអនុវត្ត** ........ ១៦
**២.៤.១. មូលទោស** ........ ១៦
២.៤.១.១. មូលទោសដែលត្រូវអនុវត្តចំពោះនីតិជន ........ ១៨
២.៤.១.២. មូលទោសដែលត្រូវអនុវត្តចំពោះអនីតិជន ........ ១៨
**២.៤.២. ទោសបន្ថែម** ........ ១៩
២.៤.២.១. ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិជន ........ ២០
២.៤.២.២. ទោសបន្ថែមដែលត្រូវអនុវត្តចំពោះអនីតិជន ........ ២១
**២.៤.៣. ទោសជំនួស** ........ ២១
២.៤.៣.១. ទោសជំនួសដែលត្រូវអនុវត្តចំពោះនីតិជន ........ ២២
២.៤.៣.២. ទោសជំនួសដែលត្រូវអនុវត្តចំពោះអនីតិជន ........ ២៣

## ជំពូកទី៣
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**៣.១. គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល** ............................ ២៤

៣.១.១. នីតិបុគ្គលមិនមែនជារដ្ឋ ............................................................ ២៤

៣.១.២. ប្រព្រឹត្តដោយអ្នកតំណាង ............................................................ ២៥

៣.១.៣. ដើម្បីផលប្រយោជន៍នីតិបុគ្គល ............................................................ ២៥

៣.១.៤. ច្បាប់ចែងជាក់លាក់ ............................................................ ២៦

**៣.២. របបនៃការទទួលខុសត្រូវរបស់នីតិបុគ្គល** ............................................................ ២៧

៣.២.១. ទោសពិន័យក្នុងឋានៈជាមូលទោស ............................................................ ២៨

៣.២.២. ទោសបន្ថែម ............................................................ ២៩

**សេចក្តីសន្និដ្ឋាន** ............................................................ ៣០

**អនុសាសន៍** ............................................................ ៣២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំនៃការស្រាវជ្រាវ

នៅក្នុងសង្គមនីមួយៗ សណ្តាប់ធ្នាប់សាធារណៈ គឺជាកត្តាដ៏សំខាន់សម្រាប់បុគ្គលគ្រប់រូបនៅគ្រប់មជ្ឈដ្ឋាននៃសង្គម។ ក៏ប៉ុន្តែដើម្បីទទួលបានសណ្តាប់ធ្នាប់សាធារណៈល្អ មិនមែនជាភាពងាយស្រួលឡើយ។ ជាទូទៅ ការសិក្សាបានបង្ហាញអំពីទំនាក់ទំនងរវាងសណ្តាប់ធ្នាប់សាធារណៈ និងស្ថិតិនៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ប្រសិនបើការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមានលក្ខណៈញឹកញាប់ នោះវាអាចឆ្លុះបញ្ចាំងអោយឃើញថាមានភាពអសន្តិសុខក្នុងសង្គម។ ផ្ទុយទៅវិញ ប្រសិនបើអត្រានៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមានកម្រិតទាប នាំឲ្យមានជាការបង្ហាញថាសណ្តាប់ធ្នាប់សាធារណៈសង្គមមានភាពល្អប្រសើរ។ ជាគោលការណ៍ដើម្បីបង្ការការកើនឡើងនៃការប្រព្រឹត្តបទល្មើស រដ្ឋបានបង្កើតបទដ្ឋានគតិយុត្តិដែលមានចរិកផ្តន្ទាទោស ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើស។ បុគ្គលនីមួយៗនៅក្រោយពេលដែលបានឆ្លងកាត់ការជំនុំជម្រះ ហើយត្រូវបានប្រកាសទោសដោយចៅក្រមជំនុំជម្រះថាមានពិរុទ្ធភាព ត្រូវទទួលរងនូវទណ្ឌកម្មដែលបានសរសេរនៅក្នុងសេចក្តីសម្រេចស្ថាពរ ដែលយោងទៅការកំណត់នៃច្បាប់។ ពោលគឺបុគ្គលនេះត្រូវទទួលទោសព្រហ្មទណ្ឌដែលមានការពិន័យជាប្រាក់ ឬការជាប់នៅក្នុងពន្ធនាគារដែលតបស្នងទៅនឹងអំពើដែលខ្លួនបានប្រព្រឹត្ត។ នៅក្នុងករណីនេះ គេអាចកំណត់បានថាបុគ្គលនោះគឺជាបុគ្គលដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាបន្ទុកដែលដាក់ចេញដោយស្ថាប័នតុលាការ ដែលធ្វើឡើងដោយគោរពទៅតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន និងសំខាន់ជាងគេគឺផ្អែកទៅលើមូលដ្ឋានច្បាប់ដែលបានចែង។ លើសពីនេះទៅទៀត ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវគោរពតាមគោលការណ៍ និងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយចំនួន។

## ២. ចំណោទបញ្ហា

តើអ្វីទៅជាការទទួលខុសត្រូវព្រហ្មទណ្ឌ? តើត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ? តើបុគ្គលប្រភេទណាដែលតុលាការអាចប្រកាសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌបាន? ហើយការប្រកាសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះធ្វើឡើងដោយឈរលើគោលការណ៍អ្វី?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរជាសារណានេះ ធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើការពង្រឹង និងពង្រីកនូវចំណេះដឹងផ្នែកច្បាប់បន្ថែមពាក់ព័ន្ធជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ដោយហេតុថាក្នុងករណីនេះមានលក្ខណៈស្មុគស្មាញ លក្ខណៈបច្ចេកទេស ពិបាកក្នុងការសិក្សាស្វែងយល់ជាងករណីផ្សេងៗទៀតនិងមានឧបសគ្គមួយចំនួនដែលពិបាកក្នុងការអនុវត្ត ទើបយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវ ដើម្បីស្រាយចម្ងល់និងស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ និងងាយស្រួលក្នុងការអនុវត្តផងដែរ។ ម្យ៉ាងទៀតការអនុវត្ត ដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ គឺជាសញ្ញាណទ្រឹស្តីនៃការអនុវត្តដែលមានលក្ខណៈថ្មីមួយ បើធៀបជាមួយនឹងក្រមព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាតាំងពីសម័យមុនៗមក។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

គួរឱ្យកត់សម្គាល់ចំពោះការបង្ហាញពីប្រធានបទដែលបានលើកឡើងខាងលើនេះ គឺធ្វើការស្រាវជ្រាវផ្តោតសំខាន់ទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសដែលត្រូវអនុវត្តនៅក្នុងប្រទេសកម្ពុជា។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងក្នុងចំណោមបញ្ហាខាងលើ ចំពោះការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះ យើងខ្ញុំបានដកស្រង់ស្រាវជ្រាវដោយផ្អែកលើឯកសារច្បាប់និងបទប្បញ្ញត្តិដែលចូលជាធរមាន និងឯកសារមកពីប្រភពផ្សេងៗដូចជា ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ មេរៀនផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទខាងលើរបាយការណ៍សិក្សា និងឯកសារផ្សេងៗរបស់លោក លោកស្រីសាស្ត្រាចារ្យសាស្ត្រាចារ្យជំនួយផ្នែកនីតិសាស្ត្រដែលចងក្រងចេញជាសៀវភៅ ឯកសារសិក្ខាសាលាផ្សេងៗ និងតាមបណ្តាញប្រព័ន្ធអ៊ិនធឺណិត ព្រមទាំងមានការចូលរួមកែសម្រួលពីបណ្តាលសាស្ត្រាចារ្យណែនាំ សិស្សច្បង និងមិត្តរួមថ្នាក់។ បន្ថែមពីនេះទៀត ក៏បានចូលសិក្សាស្រាវជ្រាវនៅបណ្ណាល័យ ដើម្បីជាប្រយោជន៍ក្នុងការស្វែងយល់ឱ្យកាន់តែច្បាស់ពី ប្រធានបទសារណានេះ ក៏ដូចជាការបំពេញបន្ថែមចំណុចផ្សេងៗទៀតផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើកាន់តែធ្វើឱ្យមានភាពស៊ីជម្រៅកាន់ច្បាស់ទៅលើប្រធានបទ និងបានជាទឡ្ហីករណ៍ក្នុងការសិក្សាឈ្វេងយល់ និងឈានដល់ការបកស្រាយនូវខ្លឹមសារទាំងមូលឱ្យបានក្បោះក្បាយ យើងខ្ញុំនឹងធ្វើការឆ្លើយតបទៅនឹងសំណួរដូចបានលើកឡើងខាងលើ ដោយធ្វើការបកស្រាយនូវខ្លឹមសារនៃប្រធានបទខាងលើ។ ប្រធានបទសារណានេះដែលបានធ្វើការបែងចែកនូវខ្លឹមសារដូចខាងក្រោម៖

- **ជំពូកទី១ ៖ សញ្ញាណគតិយុត្តិនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**
- **ជំពូកទី២ ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល**
- **ជំពូកទី៣ ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃ
# ការទទួលខុសត្រូវព្រហ្មទណ្ឌ

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

## ១.១. អត្ថន័យការទទួលខុសត្រូវព្រហ្មទណ្ឌ

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាបន្ទុកដែលដាក់ចេញដោយស្ថាប័នតុលាការ ដែលធ្វើឡើងដោយគោរពទៅតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន និងសំខាន់ជាងគេគឺទៅលើមូលដ្ឋានច្បាប់ដែលបានចែង មិនមែនចេះតែផ្តល់ទៅឲ្យបុគ្គលទាំងឡាយដែលខ្លួនសង្ស័យថាប្រព្រឹត្តបទល្មើសនោះឡើយ។ លើសពីនេះទៅទៀត ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវគោរពតាមគោលការណ៍និងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌមួយចំនួន។

## ១.២. គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺមានគោលបំណង ដើម្បីធានាថាបុគ្គលគ្រប់រូបត្រូវតែគោរពច្បាប់ទោះបីអ្នកមានប្រាក់សន្ធឹកសន្ធាប់យ៉ាងណាក៏ពុំអាចជួលអ្នកដទៃមកទទួលទោសជំនួសបានដែរ។ គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌចែកចេញជាពីរគឺ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍ឯកត្តកម្មនៃទោស។

### ១.២.១. គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ សំដៅដល់ការទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួន។ "អំពើផ្ទាល់ខ្លួន" មានន័យថា បើបុគ្គលណាម្នាក់ជាអ្នកប្រព្រឹត្តបទល្មើស ដូច្នេះបុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ ករណីបែបនេះគឺខុសពីរឿងក្តីរដ្ឋប្បវេណីមានន័យថាក្នុងរឿងក្តីរដ្ឋប្បវេណី ច្បាប់អនុញ្ញាតឲ្យអ្នកដទៃទទួលខុសត្រូវជំនួសបាន។ ប៉ុន្តែនៅក្នុងរឿងព្រហ្មទណ្ឌ អ្នកណាជាអ្នកប្រព្រឹត្តបទល្មើស អ្នកនោះគឺជាអ្នកទទួលខុសត្រូវដែលភាសាខ្មែរយើងនិយាយយ៉ាងសាមញ្ញថា "អ្នកណាធ្វើ អ្នកនោះទទួល" ហេតុនេះមិនអាចឲ្យអ្នកដទៃចូលទៅទទួលទោសជំនួសទេ ទោះបីទោសនោះជាទោសប្រភេទអ្វីក៏ដោយ។

### ១.២.២. គោលការណ៍ឯកត្តកម្មនៃទោស

គោលការណ៍ឯកត្តកម្មនៃទោស គឺតុលាការត្រូវប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ទោស និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមាយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ[1]។ ហេតុដូចនេះក្នុងមាត្រា៩៦ បានបញ្ជាក់ពីមូលដ្ឋានសំខាន់ៗទាក់ទងជាមួយនឹងអ្វីដែល

[1] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៩៦។

ចៅក្រមត្រូវដាក់ទោសមួយឲ្យវាសមស្របទៅនឹងស្ថានភាពរបស់បុគ្គលម្នាក់ៗ។ ដើម្បីងាយយល់អំពីបញ្ហានេះ យើងអាចលើកជាឧទាហរណ៍យកមកបង្ហាញជូនខ្លះថាតើបុគ្គលម្នាក់ៗទទួលទោសដោយរបៀបម៉េច? សូមលើកឧទាហរណ៍មកបញ្ជាក់ដូចខាងក្រោម៖

**ឧទាហរណ៍**៖ បទល្មើសលួច ដាក់ពន្ធនាគារពី៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី១,០០០,០០០ ( មួយលាន ) រៀល ទៅ ៦,០០០,០០០ ( ប្រាំមួយលាន ) រៀល។ ដូច្នេះ តើពេលណាគាត់ត្រូវដាក់ពន្ធនាគារ៣ឆ្នាំ? ត្រង់ចំណុចនេះ ការសម្រេចដាក់ពន្ធនាគារប៉ុន្មានខែ ឬប៉ុន្មានឆ្នាំ និងរួមទាំងការពិន័យជាប្រាក់គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម តែឆន្ទានុសិទ្ធិរបស់គាត់នេះ គឺត្រូវផ្អែកទាំងស្រុងទៅលើគោលការណ៍ឯកត្តកម្មនៃទោសបាន សេចក្តីថាត្រូវថ្លឹងថ្លែងនូវគ្រោះថ្នាក់នៃបទល្មើសដែលកើតមានដោយសារអំពើល្មើស និងចរិតគ្រោះថ្នាក់របស់បុគ្គល នៅក្នុងការជ្រើសរើសយកទោសណាមួយ ដើម្បីដាក់ឲ្យត្រូវធួនល្មមទៅតាមកម្រិតដែលគាត់បានប្រព្រឹត្ត។ ហើយពេលខ្លះទៀត ច្បាប់បានផ្តល់ជាសិទ្ធិអំណាចដល់គាត់យ៉ាងទូលំទូលាយ នៅក្នុងការចាត់ចែងទៀត ដោយឈរទៅលើមូលដ្ឋាននៃស្ថានភាពគ្រួសារ ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពសង្គម នោះចៅក្រមគាត់អាចចាត់ចែងអំពីទោសនោះបានទៀត។ គួររំលឹកផង ដែលថានៅគ្រប់ស្ថានភាពទាំងអស់ទាក់ទងនឹងការប្រកាសទោសដែលមានចែងចាប់ពីមាត្រា៩៦ តទៅនេះគឺមន្ត្រីអនុវត្តច្បាប់ ជាពិសេសគឺចៅក្រមនៃតុលាការត្រូវពឹងផ្អែកទាំងស្រុងទៅលើគោលការណ៍គ្រឹះឬគោលការណ៍ទូទៅនៃក្រមព្រហ្មទណ្ឌថ្មីនេះ។មូលហេតុគឺដោយសារតែក្រមព្រហ្មទណ្ឌចែងកំណត់នៅក្នុងមាត្រា៦ច្បាស់លាស់ណាស់ថា មានតែតុលាការមួយទេដែលមានសិទ្ធិប្រកាសពីទោសព្រហ្មទណ្ឌបានន័យថាសម្រេចអំពីទោសទណ្ឌ។

ដូច្នេះ នៅពេលចៅក្រមទាំងអស់សម្រេចទោសគ្រប់ពេលតម្រូវឲ្យចៅក្រម ដែលមានអំណាចសម្រេចទោសទាំងនោះ ត្រូវគិតទៅដល់ខ្លឹមសារដែលមានចែងក្នុងមាត្រា៩៦ និងមាត្រា២៤ ដែលជាមូលដ្ឋានក្នុងការដែលគាត់រើសយកទោសណាមួយ ឬរូបមន្តណាមួយនោះ ទៅដាក់ឲ្យត្រូវនៅក្នុងស្ថានភាពរបស់បុគ្គលម្នាក់ៗ ព្រោះថាអ្នកដែលប្រព្រឹត្តបទល្មើសគឺអាចខុសគ្នា ដូចជាជនល្មើសខ្លះប្រព្រឹត្តល្មើសជាលើកដំបូង ជនល្មើសខ្លះប្រព្រឹត្តបទល្មើសម្តងហើយម្តងទៀត ការប្រព្រឹត្តរបស់ជនល្មើសខ្លះមានចរិកលក្ខណៈកាចសាហាវខ្លាំង ចំណែកឯករណីខ្លះជនល្មើសប្រព្រឹត្តដោយសារការរំជួលចិត្តជាដើម។ ដូច្នេះ ចំណុចទាំងអស់នេះសុទ្ធតែជាមូលដ្ឋានដែលចៅក្រមយកទៅធ្វើការពិចារណា ដើម្បីផ្តន្ទាទោសបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើស។

## ១.៣. ចំណាត់ថ្នាក់នៃបទល្មើស

ក្រមព្រហ្មទណ្ឌដែលកំពុងអនុវត្តបច្ចុប្បន្ននេះ បានបញ្ញត្តិយ៉ាងជាក់លាក់អំពីលក្ខណៈវិនិច្ឆ័យនៃការកំណត់ប្រភេទនៃបទល្មើសទៅតាមទម្ងន់នៃបទល្មើសនីមួយៗ។ គួរកត់សម្គាល់ថាក្រមព្រហ្មទណ្ឌបានកំណត់យកអតិបរមានៃទោសដែលត្រូវផ្ដន្ទាទោស ពោលគឺទោសដែលច្បាប់តម្រូវឱ្យផ្ដន្ទាទោសទៅតាមប្រភេទនីមួយៗនៃបទល្មើសមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ។ បើយោងទៅតាមការបកស្រាយនៅក្នុងទូរទស្សន៍ជាតិ ដោយវាគ្មិនរបស់ក្រសួងយុត្តិធម៌ ក៏ដូចជាការបកស្រាយរបស់សាស្ត្រាចារ្យផ្សេងៗទៀត យើងឃើញថាមានការបកស្រាយយ៉ាងសាមញ្ញដូចខាងក្រោម៖

### ១.៣.១. បទលហុ

បទលហុ គឺជាបទល្មើសមួយដែលជនល្មើសបានប្រព្រឹត្តអំពើដែលនាំឱ្យប៉ះពាល់ដល់សង្គមយ៉ាងតិចតួច ស្ដួចស្ដើង ឬប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គល ហើយទណ្ឌកម្មដែលត្រូវផ្ដន្ទាទោសទៅលើជនល្មើសក៏ស្រាលផងដែរ។ បទលហុនៅក្នុងមាត្រា៤៨ នៃក្រមព្រហ្មទណ្ឌ គឺយើងមើលទៅលើគោលការណ៍ពីរយ៉ាងគឺ៖

- គោលការណ៍ទី១ មើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគាររយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ
- គោលការណ៍ទី២ មើលទៅលើបទល្មើសដែលត្រូវផ្ដន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

ដូច្នេះ យើងពិនិត្យឱ្យលម្អិតទៅឃើញថា នៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះមានបទល្មើសដែលផ្ដន្ទាទោសត្រឹមតែពិន័យជាប្រាក់ បើទោះបីជាចំនួនប្រាក់ដែលត្រូវបានពិន័យនោះប៉ុន្មានក៏ដោយ ក៏នៅតែជាបទលហុដែរ។

**ឧទាហរណ៍៖**

- បទស្រវឹងជាក់ស្ដែង ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ ( ប្រាំពាន់ ) រៀល ទៅ ១០.០០០ ( មួយម៉ឺន ) រៀល គឺពិន័យត្រឹមតែជាប្រាក់ប៉ុណ្ណោះ[2] ។
- បទហិង្សាស្រាល ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ ( ប្រាំពាន់ ) រៀល ទៅ ១០០.០០០ ( មួយសែន ) រៀល[3] ។

---

[2] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៩៧។

[3] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២២៨។

- បទបរិហារកេរ្តិ៍ជាសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ ( មួយសែន ) រៀល ទៅ ១០.០០០.០០០ ( ដប់លាន ) រៀល[4] ។
- បទជេរប្រមាថជាសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ ( មួយសែន ) រៀល ទៅ ១០.០០០.០០០ ( ដប់លាន ) រៀល[5] ។
- បទហៅអ្នកដទៃនៅទីសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ ( ប្រាំពាន់ ) រៀល ទៅ ៥០.០០០ ( ប្រាំម៉ឺន ) រៀល[6] ។

**សម្គាល់**[7]៖ ការមើលអំពីចំណាត់ថ្នាក់នៃបទល្មើស គឺត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគារ ដែលចែងនៅក្នុងច្បាប់ ឬមានចែងនៅក្នុងមាត្រានីមួយៗនៃច្បាប់ជាក់ស្តែងដែលយើងឃើញតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ មិនត្រូវមើលទៅលើអប្បបរមានៃទោសដាក់ពន្ធនាគារដែលត្រូវបានចែងក្នុងច្បាប់។ ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស នៅក្នុងករណីអនុវត្តចំពោះអនីតិជនឬសេចក្តីសម្រេចរបស់តុលាការទេ (សាលក្រម ឬ សាលដីកា)។

### ១.៣.២. បទមជ្ឈិម

បទមជ្ឈិម គឺជាបទល្មើសទាំងឡាយណាដែលស្ថិតនៅចន្លោះបទឧក្រិដ្ឋ និងបទលហុ ហើយកម្រិតគ្រោះថ្នាក់ដល់សង្គមនោះមិនធ្ងន់ធ្ងរពេកក៏មិនស្រាលពេក ហើយទោសដែលត្រូវទទួលក៏មិនធ្ងន់ធ្ងរពេក ហើយក៏មិនស្រាលពេកដែរ គឺមានលក្ខណៈធួនល្មម។ បទមជ្ឈិមត្រូវបានកំណត់អតិបរមានៃទោសដាក់ ពន្ធនាគារលើសពី ៦ ( ប្រាំមួយ ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ ( ប្រាំ ) ឆ្នាំ[8]។

**ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។**

**ឧទាហរណ៍៖**

- បទលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ( ប្រាំមួយ ) ខែ ទៅ ៣ ( បី ) ឆ្នាំ ដូច្នេះអតិបរមានៃទោសដាក់ ពន្ធនាគារដែលកំណត់ ៣ ( បី ) ឆ្នាំ គឺក្រោម ៥ ( ប្រាំ )ឆ្នាំ ដូច្នេះជាបទមជ្ឈិម[9]
- បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ឆ្នាំ ទៅ ៣ ( បី ) ឆ្នាំ[10]

[4] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣០៥។
[5] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣០៧។
[6] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៩៨។
[7] សាស្ត្រាចារ្យ កៅ សីហា, សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ, ២០២៣។
[8] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៧។
[9] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៥៦។
[10] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០៧។

- បទគំរាមកំហែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ខែ ទៅ ៦ ( ប្រាំមួយ ) ខែ[11]
- បទរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ( ប្រាំមួយ ) ថ្ងៃ ទៅ ៣ ( បី ) ខែ[12]
- បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ( ពីរ ) ឆ្នាំ ទៅ ៥ ( ប្រាំ ) ឆ្នាំ[13]

### ១.៣.៣. បទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ ហើយទោសដែលត្រូវទទួលក៏ធ្ងន់ធ្ងរផងដែរ។ យោងតាមមាត្រា៤៦ នៃក្រមព្រហ្មទណ្ឌក្នុងបទឧក្រិដ្ឋត្រូវបានកំណត់ជាពីរគឺ៖

- ទោសដាក់ពន្ធនាគារអស់មួយជីវិត
- អតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ( ប្រាំ ) ឆ្នាំឡើងទៅ និងក្រោមឬស្មើនឹង ៣០ ( សាមសិប ) ឆ្នាំ ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ។

**ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។**

**ឧទាហរណ៍៖**

- បទរំលោភសេពសន្ថវៈ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ( ប្រាំ ) ឆ្នាំ ទៅ ១០ ( ដប់ ) ឆ្នាំ ដូច្នេះ យើងឃើញថា អតិបរមានៃទោសដាក់ពន្ធនាគារសម្រាប់បទរំលោសេពសន្ថវៈ ដែលបានកំណត់អំពីអតិបរមានៃទោសដាក់ពន្ធនាគារចំនួន ១០ ( ដប់ ) ឆ្នាំ គឺជាបទឧក្រិដ្ឋ[14] ។
- បទឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[15]។
- បទទារុណកម្ម និងអំពើឃោរឃៅ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ( ប្រាំពីរ ) ឆ្នាំ ទៅ ១៥ ( ដប់ប្រាំ ) ឆ្នាំ[16]
- បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ[17] ។

---

[11] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៣១។
[12] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៥០។
[13] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៤៥។
[14] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៣៩។
[15] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០០។
[16] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២១០។
[17] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៥៦។

- បទឧបឃាត សំដៅលើអំពើប្រព្រឹត្តមួយឬច្រើន ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ ( ដប់ប្រាំ ) ឆ្នាំ ទៅ ៣០ ( សាមសិប ) ឆ្នាំ[18]។

## ១.៤. ផលប្រយោជន៍នៃការបែងចែកបទល្មើស

ការបែងចែកបទល្មើសទាំងបីប្រភេទខាងលើនេះ មានផលប្រយោជន៍ដែលច្បាប់កំណត់យក ហើយមានផលប្រយោជន៍សំខាន់ៗដូចជា៖

### ១.៤.១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល

អាជ្ញាយុកាល គឺជារយៈពេលដែលមានសិទ្ធិប្តឹង រយៈពេលដែលដើមបណ្តឹងព្រហ្មទណ្ឌមានសិទ្ធិប្តឹងពីជនល្មើស ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី[19]។ ក្នុងច្បាប់ព្រហ្មទណ្ឌ គេសង្កេតឃើញមានអាជ្ញាយុកាលពីរប្រភេទ គឺ អាជ្ញាយុកាលនៃបទល្មើស ( អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ) និងអាជ្ញាយុកាលនៃទោស។

#### ១.៤.១.១. អាជ្ញាយុកាលនៃបទល្មើស

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចនឹងធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចដាក់បណ្តឹងអាជ្ញាឱ្យមានចលនាបានឡើយ។ ចិរវេលានៃអាជ្ញាយុកាលប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងយ៉ាង ច្បាស់ថាលើកលែងតែបទប្បញ្ញត្តិនៃមាត្រា៩ ( ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់ ) នៃក្រមនេះ ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ៖

- ១៥ ( ដប់ប្រាំ ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ ( ប្រាំ ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ ( មួយ ) ឆ្នាំ ចំពោះបទលហុ[20]។

ជាគោលការណ៍ អាជ្ញាយុកាលនៃបទល្មើសត្រូវចាប់ផ្តើមចាប់ពីពេលប្រព្រឹត្តបទល្មើស។

#### ១.៤.១.២. អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសពុំអាចអនុវត្តបានទៀតទេ។ ក្រមព្រហ្មទណ្ឌ បានកំណត់ចិរវេលានៃអាជ្ញាយុកាលនៃទោសដូចតទៅ៖

[18] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៥១។
[19] សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១ លេខរៀងទី ២៣៧។
[20] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា១០។

- ទោសដែលត្រូវប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ ( ម្ភៃ ) ឆ្នាំ
- ទោសដែលត្រូវប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ ( ប្រាំ ) ឆ្នាំ
- ទោសដែលត្រូវប្រកាសពីបទលហុមានអាជ្ញាយុកាល ១ ( មួយ ) ឆ្នាំ[21]។

ចិរវេលាដែលបានកំណត់ខាងលើនេះ ត្រូវគិតចាប់ពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានក្លាយជាស្ថាពរ។

### ១.៤.២. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី

នៅក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌ អ្នកនីតិបញ្ញត្តិខ្មែរគឺកំណត់នូវគោលការណ៍មួយចំនួនដោយផ្អែកលើប្រភេទនៃបទល្មើសជាបទឧក្រិដ្ឋ ឬបទមជ្ឈិម។

**ឧទាហរណ៍៖**

- **ក្នុងករណីជាបទឧក្រិដ្ឋ**

ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ដោយធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ តាមមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះបទមជ្ឈិម ព្រះរាជអាជ្ញាមានសិទ្ធិជ្រើសរើសក្នុងការបើកការស៊ើបសួរ ឬបញ្ជូនទៅជំនុំជម្រះផ្ទាល់ឬក៏ប្រើប្រាស់នីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន បើលក្ខខណ្ឌដែលបានចែងនៅក្នុងមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។ ប្រសិនបើជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់តាមមាត្រា៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

- **ក្នុងករណីជាបទឧក្រិដ្ឋ**

ការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយចៅក្រមបីរូបដែលសម្រេចជាក្រុមសមូហភាព ឬហៅថាក្រុមប្រឹក្សាជំនុំជម្រះដោយមានការចូលរួមពីសំណាក់តំណាងអយ្យការមួយរូប។ ចំពោះបទមជ្ឈិម និងបទលហុ សាលាដំបូងជំនុំជម្រះជាចៅក្រមទោល[22]។

- **ការប៉ុនប៉ង**

តាមអត្ថន័យមាត្រា២៧ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋទាំងអស់ត្រូវតែមានទោស កាលបើលក្ខខណ្ឌដែលបានចែងនៅក្នុងមាត្រានេះត្រូវបានបំពេញគ្រប់គ្រាន់។ ជាក់ស្តែង ចាប់ពីមាត្រា ២៣៩ ដល់មាត្រា ២៤៥ នៃក្រមព្រហ្មទណ្ឌត្រូវបានបញ្ញត្តនៅក្រោមផ្នែកទី១ ស្តីពីបទរំលោភសេពសន្ថវៈនៃជំពូកទី៣ ស្តីពីការបំពានខាងផ្លូវភេទ។ នៅក្នុងបទប្បញ្ញត្តិខាងលើនេះ ពុំឃើញមានបទប្បញ្ញត្តិណាមួយដែលចែងថា ការ

[21] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៤៥។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា២៨៩។

ប៉ុនប៉ងរំលោភសេពសន្ថវៈត្រូវមានទោសទេ ក៏ប៉ុន្តែនេះមិនមានន័យថាការប៉ុនប៉ងរំលោភសេពសន្ថវៈមិនមានទោសឡើយ។ យោងតាមអត្ថន័យនៃមាត្រា២៧ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងក្នុងបទរំលោភដែលជាបទឧក្រិដ្ឋត្រូវតែទទួលការផ្តន្ទាទោស កាលបើលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា២៧ នៃក្រមព្រហ្មទណ្ឌត្រូវបានបំពេញគ្រប់ជ្រុងជ្រោយ។

ចំណែកឯការប៉ុនប៉ងក្នុងបទមជ្ឈិម ត្រូវមានទោសក្នុងករណីដែលច្បាប់បានចែងទុកជាមុនតែប៉ុណ្ណោះ។ ជាក់ស្តែងដូចជាបទប្រទូស្តកេរខ្មាស បទបង្ហាញកេរភេទ និងបទរុកកួនខាងផ្លូវភេទ ដែលមានចែងត្រង់មាត្រា២៤៦ មាត្រា២៤៩ និងមាត្រា២៥០ ស្ថិតក្នុងផ្នែកទី២ ស្តីពីការបំពានខាងផ្លូវភេទដទៃទៀត ក្នុងជំពូកទី៣ ស្តីពីការបំពានខាងផ្លូវភេទគឺជាបទមជ្ឈិម។ ហេតុនេះហើយទើបអ្នកនីតិបញ្ញត្តិបន្ថែមមាត្រា២៥១ អំពីការប៉ុនប៉ងដែលបានចែងថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទមជ្ឈិមខាងលើដែរ។

រីឯការប៉ុនប៉ងក្នុងបទលហុ ពុំត្រូវទទួលការផ្តន្ទាទោសឡើយ។

**ឧទាហរណ៍៖** ឈ្មោះ ក បានបើកបរម៉ូតូរបស់ខ្លួនបម្រុងនឹងឆ្លងកាត់ផ្លូវ ដែលមានភ្លើងសញ្ញាពណ៌ក្រហម ដោយបម្រុងនឹងឆ្លងកាត់ផ្លូវហើយ ក៏ប៉ុន្តែឈ្មោះ ក បែរជាបញ្ឈប់សកម្មភាពរបស់ខ្លួនទៅវិញ ដោយសារតែបានឃើញវត្តមានរបស់សមត្ថកិច្ចនគរបាលពីចម្ងាយ ។ អំពើរបស់ឈ្មោះ ក គឺជាការប៉ុនប៉ងប្រព្រឹត្តបទលហុដែលមិនត្រូវមាន ទោសឡើយ ។

- **ការផ្តើមគំនិត និងការសមគំនិត**

ការផ្តើមគំនិត និងការសមគំនិតដែលបំពេញលក្ខខណ្ឌច្បាប់កំណត់ ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម សុទ្ធសឹងតែមានទោសទាំងអស់[23]។ ប៉ុន្តែមាត្រា២៨ និង មាត្រា២៩នៃក្រមព្រហ្មទណ្ឌពុំបានចែងពីការផ្តើមគំនិត ឬការសមគំនិត ក្នុងបទលហុទេគឺមានន័យថាការផ្តើមគំនិត និងការសមគំនិតក្នុងបទលហុ មិនត្រូវទទួលការ ផ្តន្ទាទោសឡើយ ។

**ឧទាហរណ៍៖** កាលពីថ្ងៃទី១៥ ខែវិច្ឆកា ឆ្នាំ២០២០ នៅក្នុងក្រុងព្រះសីហនុ ចារីម្នាក់ឈ្មោះ តារា បានជួញដូរគ្រឿងញៀនដែលជាប្រភេទមេតំហ្វេមីន ៩៥ក្រាម។ នៅពេលដែលធ្វើសកម្មភាពជួញដូរ ត្រូវបានឃាត់ខ្លួននិងសួរនាំពីនគរបាលក្រុងព្រះសីហនុ។ តារា បានអះអាងថាខ្លួនបានទទួលលេខទូរស័ព្ទរបស់អ្នកលក់គ្រឿងញៀនពីលោក ហួសានី។ ដូច្នេះ តុលាការបានចេញសេចក្តីសម្រេចផ្តន្ទាទោសលោក ហួសានី ពីបទសមគំនិត។

[23] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៨ និងមាត្រា២៩ ។

# ជំពូកទី២
# ការទទួលខុសត្រូវ
# ព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

# ជំពូកទី២
# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល

រូបវន្តបុគ្គលសំដៅលើមនុស្សដែលមានជីវិតពិតពីធម្មជាតិដែលផ្ទុយពីនីតិបុគ្គល[24]។ នៅពេលដែលអំពើមួយប្រព្រឹត្តឡើងបង្កឲ្យមានការខូចខាតដល់ទំនាក់ទំនងសង្គមដែលច្បាប់ព្រហ្មទណ្ឌបានការពារ ហើយអំពើនោះបានបំពេញធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ត្រូវចាត់ទុកជាបទល្មើស។ សម្រាប់ជនដែលបានប្រព្រឹត្តអំពើនោះត្រូវចាត់ទុកជាជនល្មើស ដោយឡែកការទទួលខុសត្រូវខាងព្រហ្មទណ្ឌវិញ គឺអាស្រ័យដោយស្ថានភាពខាងផ្លូវច្បាប់របស់ជនល្មើសនិងខាងអំពើ។ នៅក្នុងចំណុចនេះជនល្មើសត្រូវបានកំណត់ថាមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមកម្រិតអាយុ និងការយល់ដឹងនូវអំពើដែលខ្លួនបានប្រព្រឹត្ត។

ផ្អែកតាមស្មារតីនៃក្រមព្រហ្មទណ្ឌ ជនដែលបានប្រព្រឹត្តបទល្មើសជារូបវន្តបុគ្គល អាចប្រកាសឲ្យទទួលខុសត្រូវខាងព្រហ្មទណ្ឌអាស្រ័យដោយកម្រិតអាយុ។ ហើយការកម្រិតអាយុរបស់រូបវន្តបុគ្គលនេះត្រូវបានគេបែងចែកចេញជាពីរគឺនីតិជន និងអនីតិជន៖

## ២.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជនត្រូវបានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ[25]។ នីតិជនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពេញលេញ នេះជាការចែងទុកជាមុនរបស់ច្បាប់ដោយកំណត់នូវកម្រិតអាយុក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចាប់ពី១៨ឆ្នាំឡើងទៅ មានន័យថាឆន្ទៈសង្គមរបស់មនុស្សភាគច្រើនតាមរយៈតំណាងរាស្ត្រ បានបញ្ញត្តិច្បាប់ឡើងដោយទទួលស្គាល់ថារូបវន្តនៅពេលមានអាយុ១៨ឆ្នាំឡើងទៅ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិចារណាអំពីអំពើដែលខ្លួនបានប្រព្រឹត្ត និងបច្ច័យដែលកើតចេញពីសកម្មភាពរបស់ខ្លួន ហើយមានសមត្ថភាពខាងផ្លូវច្បាប់គ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។ គួសបញ្ជាក់ឡើងវិញផងដែរថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន ត្រូវបានស្តែងឡើងតាមទោសព្រហ្មទណ្ឌ ឬទណ្ឌកម្មដែលត្រូវប្រកាសដោយតុលាការព្រហ្មទណ្ឌ។

## ២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌអនីតិជន

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវបានកំណត់ចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ប្រសិនបើមានកាលៈទេសៈនៃបទល្មើស និងលក្ខណៈរបស់អនីតិជននោះតម្រូវ[26]។

---

[24] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧,ទំព័រ១៩។

[25] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨។

[26] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩។

អនីតិជន សំដៅលើជនដែលមានអាយុក្រោម ១៨ ( ដប់ប្រាំបី ) ឆ្នាំ[27]។ ចំពោះការទទួលខុសត្រូវរបស់អនីតិជន មានពីរប្រភេទគឺៈ

### ២.២.១. អនីតិជនអាយុក្រោម១៤ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ ( ដប់បួន ) ឆ្នាំនេះ គឺច្បាប់បានកំណត់ថាមិនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ មានន័យថានៅពេលដែលបុគ្គលដែលមានអាយុក្រោម ១៤ ( ដប់បួន ) ឆ្នាំ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ បុគ្គលនោះមិនអាចត្រូវបានដាក់ទោសព្រហ្មទណ្ឌទៅលើរូបគាត់បានឡើយ[28]។

### ២.២.២. អនីតិជនអាយុចាប់ពី១៤ឆ្នាំទៅដល់ក្រោម១៨ឆ្នាំ

អនីតិជនប្រភេទនេះ នៅពេលដែលបានប្រព្រឹត្តបទល្មើស គឺបុគ្គលនេះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ តុលាការត្រូវថ្លឹងថ្លែងពាក់ព័ន្ធទៅជាមួយនឹងកាលៈទេសៈនៃបទល្មើស ដែលគាត់ប្រព្រឹត្តនិងបុគ្គលិកលក្ខណៈរបស់បុគ្គលនេះ។ ដោយហេតុថា អនីតិជនដែលប្រព្រឹត្តបទល្មើស វិធានការនៅក្នុងការដាក់ទណ្ឌកម្មសម្រាប់អនីតិជនប្រភេទនេះ គឺក្នុងគោលដៅធ្វើការតាមដានអប់រំ ការពារ ឬការឧបត្ថម្ភផ្សេងៗដល់គាត់[29]។ ប្រភេទនៃវិធានការតាមដានវិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅៈ

- ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។
- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។
- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។
- ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ។

---

[27] សន្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, ទំព័រ២៧។

[28] មាត្រា១០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

[29] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩។

ដូច្នេះ ទាក់ទងជាមួយនឹងការទទួលខុសត្រូវរបស់អនីតិជន ដែលមានអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ទៅដល់ អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល គ្រាន់តែស្ថានភាពដែលថា ទទួលឱ្យដូចនីតិជនតែម្តងគឺមិនដូចទេ ព្រោះមានកម្រិតស្រាលជាង។

## ២.៣. លក្ខខណ្ឌទាក់ទងបុគ្គលដែលបានចូលរួម

### ២.៣.១. ចារី

ចារី គឺជាបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម[30]។ តាមរយៈនេះចារី គឺសំដៅទៅដល់បុគ្គលម្នាក់ដែលបានប្រព្រឹត្តឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ ហើយដែលច្បាប់មានចែងទុក។

**ឧទាហរណ៍៖** លោក ណារ៉ុង បានធ្វើសកម្មភាពសម្លាប់លោកស្រី ពិសី នៅភូមិស្រែថ្កុង ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ ហើយត្រូវបានប៉ូលីសចាប់បាន។ ក្នុងករណីនេះ លោក ណារ៉ុង បានប្រព្រឹត្តបទល្មើស ឃាតកម្មដែលមានចែងក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។ ដូចនេះ លោក ណារ៉ុង ចាត់ទុកជាចារី។

### ២.៣.២. សហចារី

សហចារី កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងគ្នាប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ ក្នុងករណីដែលច្បាប់បានចែងទុក[31]។ តាមរយៈនេះសហចារី គឺសំដៅទៅដល់បុគ្គលចាប់ពីពីរនាក់ឡើងទៅព្រមព្រៀងគ្នាប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ដែលច្បាប់ចែងទុក។

**ឧទាហរណ៍៖** លោក ក ខ គ ឃ ង បានព្រមព្រៀងគ្នាធ្វើសកម្មភាពជួញដូរគ្រឿងញៀន ហើយត្រូវបានប៉ូលីសចាប់ខ្លួនកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលបានប្រព្រឹត្តនៅចំណុចភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ។ ក្នុងករណីនេះ ក ខ គ ឃ ង បានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបានចែងក្នុងមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូចនេះ ក ខ គ ឃ ង ចាត់ទុកជាសហចារី ដូចចែងក្នុងមាត្រា២៦។

[30] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៥។

[31] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៦។

### ២.៣.៣. ការចូលរួមប្រព្រឹត្តបទល្មើសដោយប្រយោល

ក្រៅពីបុគ្គលដែលបានប្រព្រឹត្ត និងបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ដូចបានរៀបរាប់ខាងលើ ហើយក៏តាមទិដ្ឋភាពជាក់ស្តែង ឃើញថានៅមានបុគ្គលមួយចំនួនទៀតដែលបានចូលរួមជួយសម្រួល ក៏ដូចជាជម្រុញអោយការប្រព្រឹត្តបទល្មើសមួយបានសម្រេចផងដែរ។ ក្រមព្រហ្មទណ្ឌបានចែង និងកំណត់ពីឋានៈបុគ្គលប្រភេទនេះផងដែររួមមាន អ្នកផ្តើមគំនិត និងអ្នកសមគំនិត។

#### ២.៣.៣.១. អ្នកផ្តើមគំនិត

អ្នកផ្តើមគំនិត គឺជាបុគ្គលដែលជម្រុញអោយប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមតាមការណែនាំ ឬការបញ្ជាអ្នកណាម្នាក់អោយប្រព្រឹត្តបទល្មើសណាមួយ[32]។ អ្នកផ្តើមគំនិត ក៏ជាបុគ្គលដែលបង្កអោយមានបទល្មើសដោយ ផ្តល់អំណោយដោយការសន្យាឬការគំរាមកំហែង ការញុះញង់ លួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួនផងដែរ។ អ្នកផ្តើមគំនិតអាចត្រូវបានផ្តន្ទាទោសបានដរាបណាបទល្មើសនោះបានសម្រេច ឬបានប៉ុនប៉ងមានន័យថាក្នុងករណីដែលបុគ្គលម្នាក់បានផ្តួចផ្តើមគំនិតជំរុញអោយបុគ្គលម្នាក់ឬច្រើននាក់ទៀតប្រព្រឹត្តបទល្មើសតែបុគ្គលទាំងនោះមិនបានទៅប្រព្រឹត្តបទល្មើសតាមការជំរុញទេ នោះអ្នកផ្តើមគំនិតត្រូវសន្មត់ថាគ្មានទោសផងដែរ។ តែក្នុងករណីមានបទល្មើសកើតឡើង អ្នកផ្តើមគំនិតត្រូវទទួលទោសដូចចារីផងដែរ។

**ឧទាហរណ៍៖** លោក ក បានញុះញង់ លោក ខ ថា លោក គ បាននិយាយចំអកពីលោក ខ ថា លោក ខ ជាមនុស្សកំសាកមិនហ៊ានធ្វើអ្វីលើខ្លួនទេទោះជាខ្លួនជេរប្រមាទ លោក ខ យ៉ាងណាក៏ដោយហើយកក៏បានញុះញង់៩ លោក ខ ទៅវៃ លោក គ ដើម្បីបង្ហាញពីអានុភាពរបស់ខ្លួន។ ប៉ុន្មានថ្ងៃក្រោយ លោក ខ ក៏បានទៅវាយ លោក គ រហូតដល់របួសធ្ងន់ចូលសំរាកព្យាបាលនៅមន្ទីរពេទ្យ។ ប៉ូលីសក៏បានមកចាប់ លោក ខ ហើយ លោក ខ បានសារភាពថាខ្លួនពិតជាបានទៅវៃ លោក គ ពិតមែនដោយស្តាប់តាមការញុះញង់របស់ លោក ក។ ក្នុងករណីនេះ លោក ខ ជាចារីប្រព្រឹត្តបទល្មើសហើយ លោក ក ជាអ្នកផ្តើមគំនិតដែលត្រូវទទួលទោសដូចនឹងចារីផងដែរ។

#### ២.៣.៣.២. អ្នកសមគំនិត

អ្នកសមគំនិត គឺជាបុគ្គលដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន[33]។ អ្នកសមគំនិតក៏ដូចគ្នាទៅនឹងអ្នកផ្តើមគំនិតផងដែរ គឺអាចត្រូវបានផ្តន្ទាទោសបានលុះត្រាតែបទល្មើសនោះបានសម្រេច ឬបានប៉ុនប៉ង។ អ្នកសមគំនិត ក៏អាចត្រូវបានផ្តន្ទាទោសដូចគ្នាទៅនឹងចារីផងដែរ។

---

[32] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៨។

[33] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៩។

**ឧទាហរណ៍៖** ក បានចូលទៅលួចទ្រព្យសម្បត្តិមួយចំនួនក្នុងផ្ទះរបស់គេ។ ក្នុងពេលចូលទៅលួច ខ ជាអ្នកមើលផ្លូវអោយ ក ដើម្បីការពារខ្លាចមានគេមកទាន់។ ក បានលួចធ្វើសកម្មភាពរួចរាល់ក៏បានចេញមកវិញ ហើយឡើងម៉ូតូជាមួយ ខ រួចជិះចេញទៅដោយសុវត្ថិភាព។ ក្នុងករណីនេះ ក ជាចារី ហើយ ខ ជាអ្នកសមគំនិត។

## ២.៤. ទោសដែលត្រូវអនុវត្ត

យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ ដូច្នេះ បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសដែលច្បាប់ព្រហ្មទណ្ឌបានចែងថាមានទោសនោះ បុគ្គលនោះនឹងត្រូវទទួលរងនូវទណ្ឌកម្មចំពោះអំពើរបស់ខ្លួន។ ប៉ុន្តែតុលាការប្រកាសទោសដោយ ផ្អែកលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុកទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ។ ចំពោះការទទួលទណ្ឌកម្មសម្រាប់រូបវន្តបុគ្គលត្រូវបានបែងចែកជាពីរគឺ៖

- ការទទួលទណ្ឌកម្មសម្រាប់នីតិជន
- ការទទួលទណ្ឌកម្មសម្រាប់អនីតិជន។

### ២.៤.១. មូលទោស

មូលទោស គឺជាទោសដាក់ពន្ធនាគារ និងទោសពិន័យ[34]។ មូលទោស សំដៅទៅលើទោសសំខាន់ចម្បងជាងគេ ដែលតុលាការអាចប្រកាសយកទៅសម្រេចដាច់តែឯងបានដោយមិនចាំបាច់បញ្ចូលនូវទោសបន្ថែម ឬទោសជំនួសក៏បានដែរពោលជាទោសសំខាន់ជាងគេ។ មូលទោសត្រូវបានបែងចែកជាពីរគឺទោសដាក់ពន្ធនាគារនិងទោសពិន័យជាប្រាក់។ ការកំណត់នៃទោសនីមួយៗគឺជាគោលការណ៍ដែលស្របតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌបានកំណត់អប្បបរមា និងអតិបរមានៃទោសនីមួយៗ មានន័យថាអប្បបរមានៃទោសដាក់ពន្ធនាគារ អតិបរមានៃទោសដាក់ពន្ធនាគារ អប្បបរមានិងអតិបរមានៃទោសពិន័យជាប្រាក់។ ចំពោះ អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ គឺអាចនឹងត្រូវបានបន្ថយឬបន្ថែមក្នុងលក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ ដូចជាករណីដែលមានស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសចំពោះបទល្មើសដែលជននោះបានប្រព្រឹត្ត។

[34] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៣។

ចំពោះទោសដាក់ពន្ធនាគារ គឺជាទោសដែលត្រូវបានបំបាត់ស្ទើតែទាំងអស់នូវរាល់សេរីភាពជាមូលដ្ឋានដោយមានកំណត់កាល។ ស្របគ្នានឹងនេះផងដែលនៅក្នុងការកំណត់ពីទោសដាក់ពន្ធនាគារ ច្បាប់ត្រូវកំណត់អំពីកម្រិតអប្បបរមា និងអតិបរមានៃទោស[35]។ ទោសដាក់ពន្ធនាគារអាចជាទោសដាក់ពន្ធនាគារអស់មួយជីវិត ទោសដាក់ពន្ធនាគារមានរយៈពេល។ ទោសដាក់ពន្ធនាគារមានរយៈពេលអាចជាទោសដាក់ពន្ធនាគារមានរយៈពេលចាប់ពី១ថ្ងៃ រហូតដល់៣០ឆ្នាំ[36]។

ក្រមព្រហ្មទណ្ឌបានចែងអំពីចិរវេលានៃទោសដាក់ពន្ធនាគារ ដែលបានកំណត់ដូចខាងក្រោម៖

- ប្រសិនបើទោសដាក់ពន្ធនាគារកំណត់ដាក់រយៈពេល ១ ( មួយ ) ថ្ងៃ ដូច្នេះច្បាប់កំណត់ថា ១ ( មួយ ) ថ្ងៃនេះគឺមានរយៈពេល ២៤ ( ម្ភៃបួន ) ម៉ោង។
- បើជនម្នាក់ ត្រូវបានតុលាការសម្រេចដាក់ពន្ធនាគារ ១ ( មួយ ) ខែ របៀបក្នុងការគណនា ១ ( មួយ ) ខែ ត្រូវគិត៣០ ( សាមសិប ) ថ្ងៃ។ ទោសដាក់ពន្ធនាគារលើសពី ១ ( មួយ ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែង ដែលមាននៅក្នុងខែនោះ។
- បើសិនជនម្នាក់ ត្រូវបានតុលាការដាក់ពន្ធនាគារ ១( មួយ ) ឆ្នាំ របៀបនៃការគណនាត្រូវគិត ១២ (ដប់ពីរ) ខែ[37]។

ទន្ទឹមនឹងនេះ ក្រមព្រហ្មទណ្ឌក៏បានចែងអំពីលក្ខខណ្ឌនៃការបញ្ចប់ទោសផងដែរ។ ជាទូទៅ នៅពេលដែលតុលាការ បានផ្តន្ទាទោសដាក់ពន្ធនាគារជនណាម្នាក់ហើយ នៅក្នុងករណីនេះជននោះត្រូវទទួលរងទោសឱ្យបានគ្រប់ចំនួន ដូចជា ៣ ( បី ) ឆ្នាំ ត្រូវទទួលរងឱ្យបានគ្រប់ចំនួន ៣ ( បី ) ឆ្នាំ ប៉ុន្តែមានករណីពិសេសខ្លះដែលក្នុងនោះការបញ្ចប់ទោសដាក់ពន្ធនាគារអាចចប់មុនបាន ក្នុងករណីដែលការបញ្ចប់ទោសនោះចំថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាក ដែលច្បាប់ឬបទដ្ឋានគតិយុត្តបានកំណត់។ ដូច្នេះទណ្ឌិតនោះត្រូវបានដោះលែងឱ្យមាន សេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ។ ក្រមព្រហ្មទណ្ឌក៏បានចែងអំពីការគិតរាប់បញ្ចូលចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចូលទៅក្នុងចិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួលផងដែរ។

ចំពោះទោសពិន័យជាប្រាក់វិញ ការពិន័យជាប្រាក់ត្រូវគិតជាប្រាក់រៀលដែលជារូបិយវត្ថុជាតិ ហើយផលដែលបានចេញពីការពិន័យជាប្រាក់នេះត្រូវបង់ចូលទៅក្នុងថវិការដ្ឋ[38]។ ទោសពិន័យជាប្រាក់នេះ ខុសពីទោសដែលសម្រេចផ្តន្ទាទោសឱ្យសងជម្ងឺចិត្ត។ ទោសពិន័យ ជាប្រភេទនៃទោសព្រហ្មទណ្ឌគឺខុសពីទោសទណ្ឌកម្ម

---

[35] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩,មាត្រា៤៤ កថាខណ្ឌទី១។
[36] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩,មាត្រា៤៦ កថាខណ្ឌទី១ ចំណុចទី២
[37] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩,មាត្រា៤៩។
[38] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩,មាត្រា៥២។

ផ្សេងទៀត ដែលចៅក្រមប្រកាសផ្តន្ទាទោសដូចជាជនម្នាក់បានប្រព្រឹត្តបទល្មើស ចៅក្រមសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារផង ហើយសម្រេចឱ្យជនជាប់ចោទនោះបង់ជម្ងឺចិត្តទៅឱ្យជនរងគ្រោះទៀតផង។ សំណងជម្ងឺចិត្តត្រូវបង់ទៅឱ្យជនរងគ្រោះ និងត្រូវគិតគូរទៅតាមទំហំនៃព្យសនកម្ម ប៉ុន្តែប្រាក់ពិន័យវិញ គឺចៅក្រមមិនអាចធ្វើអ្វីខុសពីការកំណត់របស់ច្បាប់ទេ មានន័យថាច្បាប់បានកំណត់ជាស្រេចអំពីអប្បបរមា និងអតិបរមាដែលត្រូវរងចំពោះការពិន័យ។

**២.៤.១.១. មូលទោសដែលត្រូវអនុវត្តចំពោះនីតិជន**

នីតិជន ជាជនដែលមានអាយុ ១៨ ( ដប់ប្រាំបី ) ឆ្នាំឡើងទៅ។

ដើម្បីកំណត់ទោសទៅលើបទល្មើសណាមួយបាន លុះត្រាតែយើងសង្កេតមើលទៅលើលក្ខណៈសម្គាល់នៃបទល្មើសនីមួយៗ។ ដើម្បីអាចសម្គាល់ថាបទល្មើសណាមួយជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុនោះ យើងត្រូវពិនិត្យទៅលើមូលទោស។

យោងតាមក្រមព្រហ្មទណ្ឌ មាត្រា៤៦ មាត្រា៤៧ និងមាត្រា៤៨ បានកំណត់អំពីរបៀបក្នុងការសម្គាល់ថា បទល្មើសមួយជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុបានតាមរយៈទោសដាក់ពន្ធនាគារក្នុងករណី៖

- ទោសដាក់ពន្ធនាគារនោះជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលកំណត់ ប៉ុន្តែលើសពី ៥ ( ប្រាំ ) ឆ្នាំឡើងទៅ ដល់ក្រោម ឬស្មើនឹង ៣០ ( សាមសិប ) ឆ្នាំ នៅក្នុងករណីនេះច្បាប់បានកំណត់ថាជាបទឧក្រិដ្ឋ។
- ទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ ( ប្រាំមួយ ) ថ្ងៃ ដល់ក្រោម ឬស្មើនឹង ៥ ( ប្រាំ ) ឆ្នាំ ក្រមព្រហ្មទណ្ឌចាត់ទុកថាបទល្មើសនោះជាបទមជ្ឈិម។
- ចំពោះបទលហុ មានលក្ខខណ្ឌវិនិច្ឆ័យពីរគឺ ការមើលទៅលើទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានអតិបរមាក្រោម ឬស្មើនឹង ៦ ( ប្រាំមួយ ) ថ្ងៃ និងទោសត្រឹមតែពិន័យជាប្រាក់។

**២.៤.១.២. មូលទោសដែលត្រូវអនុវត្តចំពោះអនីតិជន**

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ[39]។

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដានវិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ តុលាការអាចប្រកាសទណ្ឌកម្មទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ( ដប់បួន ) ឆ្នាំឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ[40]។

[39] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៨។
[40] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣៩។

កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ( ដប់បួន ) ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់នោះ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវកាត់បន្ថយពាក់កណ្តាល
- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិតអតិបរមាត្រូវបន្ថយ មកដាក់ពន្ធនាគារ ២០ ( ម្ភៃ ) ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានោះលើសពី ១ ( មួយ ) ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិខាងលើមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ ( ប្រាំ ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល[41]។

ចំពោះអនីតិជនដែលមានអាយុតិចជាង ១៤ ( ដប់បួន ) ឆ្នាំ តុលាការមិនអាចប្រកាសទោសចំពោះអំពើរបស់អនីតិជននោះបានឡើយ។ សម្រាប់អនីតិជន ដែលត្រូវបានជាប់ពន្ធនាគារត្រូវឃុំខ្លួននៅទីកន្លែងពិសេស ត្រូវបានខណ្ឌដាច់ពីនីតិជន។ អនីតិជន ស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ[42]។

### ២.៤.២. ទោសបន្ថែម

ទោសបន្ថែម សំដៅដល់ប្រភេទនៃទោសមួយដែលបន្ថែមទៅលើមូលទោសមានន័យថា ជាទូទៅនៅពេលចៅក្រមប្រកាសមូលទោសហើយ ក្នុងករណីដែលមានច្បាប់ចែងអំពីការផ្តន្ទាទោសបន្ថែមចំពោះបទល្មើសនោះ ទោសបន្ថែមអាចត្រូវបានប្រកាស។ ទោសបន្ថែម គឺជាអនុទោស ឬទោសបន្ទាប់បន្សំ ដែលសំដៅដល់ទោសដែលត្រូវដាក់បញ្ចូលទៅក្នុងមូលទោស។ ការដាក់បញ្ចូលទៅក្នុងមូលទោសនេះ សំដៅដល់ការបន្ថែមទៅលើមូលទោស ឬដាក់ជំនួសមូលទោស។ ទោសបន្ថែម បង្កើតឡើងក្នុងគោលបំណងឲ្យការដាក់ទណ្ឌកម្មមានកម្រិតសមស្របទៅនឹង អំពើល្មើស ដែលបានប្រព្រឹត្ត ឬនិយាយម្យ៉ាងទៀតថា ដើម្បីធានាដល់ការអនុវត្តគោលការណ៍ឯកត្តកម្មនៃទោស។ ទោសបន្ថែម គឺជាទោសដែលចៅក្រមមិនអាចយកទៅសម្រេចដាក់តែឯងបាននោះទេ គឺថាចៅក្រមនឹងសម្រេចទោសបន្ថែមណាមួយបាន លុះត្រាតែបានសម្រេចមូលទោសណាមួយសិនគឺ

[41] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦០។
[42] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦៦។

ទោសបន្ថែមគ្រាន់តែជាកម្មវិបាករបស់មូលទោសតែប៉ុណ្ណោះ។ និយាយម៉្យាងទៀតថា ទោសបន្ថែមជាទោសដែលតុលាការប្រកាសបន្ថែមទៅលើមូលទោស និងមានចែងយ៉ាងជាក់លាក់ដោយបញ្ញត្តិដែលបង្ក្រាបបទល្មើស ( មាត្រា ៥៣ និង ៥៥ នៃក្រមព្រហ្មទណ្ឌ ) ។ ទោសបន្ថែមមានគោលដៅបំពេញបន្ថែមឲ្យមូលទោសដើម្បីបង្ការការប្រព្រឹត្តបទល្មើសសាជាថ្មី។

ទោសបន្ថែម អាចប្រកាសទោសបានលុះត្រាតែទោសនោះត្រូវបានចែងដោយជាក់លាក់ចំពោះ បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ក្នុងករណីច្បាប់កំណត់ថា ទោសបន្ថែមត្រូវតែប្រកាសជាកាតព្វកិច្ចនោះតុលាការត្រូវតែប្រកាសទោសបន្ថែមជាដាច់ខាត ( មាត្រា ៥៤ នៃក្រមព្រហ្មទណ្ឌ )។ ទោសបន្ថែម អាចប្រកាសទៅបានលុះត្រាតែទោសនោះមានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសណាដែលត្រូវចោទប្រកាន់។

**២.៤.២.១. ទោសបន្ថែមដែលត្រូវអនុវត្តចំពោះនីតិជន**

តុលាការអាចប្រកាសទោសបន្ថែមទៅលើជនដែលប្រព្រឹត្តបទល្មើស ដែលជានីតិជនមួយ ឬច្រើនបាន។ ទោសបន្ថែមដែលអាចអនុវត្តចំពោះនីតិជនមានដូចជា៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈ
- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ
- ការព្យួរលិខិតបើកបរ
- ការហាមឃាត់ចំពោះការស្នាក់នៅ
- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា
- ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត

- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ
- ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណៈជន ឬ ដែលប្រើប្រាស់ដោយសាធារណៈជន
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារពត៌មាន
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍[43]។

ទោសបន្ថែមនេះត្រូវបានកំណត់យ៉ាងជាក់លាក់នៅក្នុងក្រមព្រហ្មទណ្ឌ ហើយក៏បានកំណត់អំពីចិរវេលានៃការអនុវត្តចំពោះទោសបន្ថែមនេះផងដែរ។ ទោសបន្ថែមនឹងអាចប្រកាសទៅបានលុះត្រាតែទោសនេះត្រូវបានចែង ដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវចោទប្រកាន់។ ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ចប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់[44]។

#### ២.៤.២.២. ទោសបន្ថែមដែលត្រូវអនុវត្តចំពោះអនីតិជន

ទោសបន្ថែមដែលអនុវត្តចំពោះអនីតិជន មានលក្ខណៈខុសពីទោសបន្ថែមដែលអនុវត្តចំពោះនីតិជន។ ក្រមព្រហ្មទណ្ឌ បានកំណត់យ៉ាងជាក់លាក់អំពីទោសបន្ថែម ដែលអាចអនុវត្តចំពោះអនីតិជនមានដូចតទៅ៖

- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ការហាមឃាត់ការកាន់កាប់ ឬការយកមកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ[45]។

### ២.៤.៣. ទោសជំនួស

ទោសជំនួស គឺជាប្រភេទទោសមួយដែលចៅក្រមអាចជ្រើសរើសយកទៅប្រើប្រាស់ ដើម្បីជំនួសឱ្យមូលទោស មានន័យថាទោសនេះត្រូវបានយកទៅប្រើប្រាស់ជំនួសឱ្យមូលទោស។ នៅពេលដែលចៅក្រម ឬ

[43] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥៣។
[44] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥៤។
[45] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦១។

តុលាការប្រកាសប្រើប្រាស់ទោសជំនួសនេះ ចៅក្រមមិនប្រកាសមូលទោសទេ គឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ យោងតាមក្រមព្រហ្មទណ្ឌ ទោសជំនួសត្រូវបានចែកចេញជាពីរប្រភេទគឺ ទោសការងារសហគមន៍ និងទោសស្តីបន្ទោស។

- **ទោសការងារសហគមន៍**

ទោសការងារសហគមន៍ គឺសំដៅលើកាតព្វកិច្ចមួយដែលត្រូវបំពេញនូវការងារមួយដែលគ្មានកម្រៃ និងជាប្រយោជន៍រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។

- **ទោសស្តីបន្ទោស**

ទោសស្តីបន្ទោស ជាទោសដែលប្រើប្រាស់សម្រាប់បទល្មើសស្រាល ហើយចៅក្រមមិនសម្រេចដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ទេ។ ដូច្នេះចៅក្រមអាចប្រកាសទោសនេះបានទុកជាការព្រមានអំពីកំហុសខុសឆ្គងដែលជនជាប់ចោទបានប្រព្រឹត្ត និងដើម្បីកុំឱ្យជននោះប្រព្រឹត្តបទល្មើសតទៅទៀត។

**២.៤.៣.១. ទោសជំនួសដែលត្រូវអនុវត្តចំពោះនីតិជន**

តុលាការ អាចប្រកាសទោសការងារសហគមន៍ទៅលើនីតិជនបាន។

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣ ( បី ) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍[46] ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ ( សាមសិប ) ម៉ោង ទៅ ២០០ ( ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល[47] ។

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ[48]។

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាអាទិ៍ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី[49]។

[46] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៧២ កថាខណ្ឌទី១។
[47] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៧២ កថាខណ្ឌទី២។
[48] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៧៣។
[49] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៧៤ កថាខណ្ឌទី១។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ[50]។

ដើម្បីអាចប្រកាសទោសនេះបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅពេលសវនាការ ហើយបានយល់ព្រមធ្វើការនេះ។

ចំណែកឯទោសស្ដីបន្ទោសវិញ អាចត្រូវបានប្រកាសដោយតុលាការ ក្នុងករណីដែលជនជាប់ចោទទទួល ទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង៣ (បី) ឆ្នាំ និងត្រូវគោរពលក្ខខណ្ឌដូចជា៖

- ភាពចលាចលសណ្ដាប់ធ្នាប់សាធារណៈដែលបណ្ដាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ[51]។

**២.៤.៣.២. ទោសជំនួសដែលត្រូវអនុវត្តចំពោះអនីតិជន**

តុលាការអាចប្រកាសទោសការងារសហគមន៍សម្រាប់អនីតិជនបាន លុះត្រាតែអនីតិជននោះមានអាយុ យ៉ាងតិច ១៦ ( ដប់ប្រាំមួយ ) ឆ្នាំ ដល់ក្រោម ១៨ ( ដប់ប្រាំបី ) ឆ្នាំ ហើយថិរវេលានៃការងារមិនអាចលើសពី ១០០ ( មួយរយ ) ម៉ោងបានទេ[52]។

ចំពោះទោសការងារសហគមន៍នេះគឺត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្ដុះបណ្ដាល អប់រំ កែប្រែ ដើម្បីសម្រួលដល់អនីតិជនចូលរួមរស់នៅក្នុងសង្គមវិញ[53]។ តុលាការមិនអាចប្រកាសទោសការងារសហគមន៍ទៅលើអនីតិជនដែលមានអាយុតិចជាង ១៦ ( ដប់ប្រាំមួយ ) ឆ្នាំបានឡើយ។

សម្រាប់ទោសស្ដីបន្ទោសវិញ លក្ខខណ្ឌនៃការប្រកាសទោសស្ដីបន្ទោសនេះ គឺបានកំណត់ខាងលើនូវចំណុចទោសជំនួសអនុវត្តចំពោះនីតិជនរួចមកហើយ។

ក្នុងករណីដែលតុលាការប្រកាសទោសជំនួស ដែលជាទោសការងារសហគមន៍ ឬទោសស្ដីបន្ទោសជំនួសអោយមូលទោសនោះ តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់បានទេ[54]។

[50] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៧៤ កថាខណ្ឌទី២។

[51] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៧៦។

[52] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦២ កថាខណ្ឌទី១

[53] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦២ កថាខណ្ឌទី២។

[54] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៩៨។

# ជំពូកទី៣

# ការទទួលខុសត្រូវ

# ព្រហ្មទណ្ឌរបស់និតិបុគ្គល

# ជំពូកទី៣
# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

## ៣.១. គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

ជាគោលការណ៍ ការទទួលខុសត្រូវព្រហ្មទណ្ឌបានបង្កើតឡើងសំរាប់តែមនុស្សប៉ុណ្ណោះ។ ក៏ប៉ុន្តែចំពោះក្រមព្រហ្មទណ្ឌបានបញ្ចូលទៅក្នុងនីតិខ្មែរ នូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ។

នេះជានវកម្មជាសារវន្តមួយដែលមានគោលដៅបំពេញនូវកង្វះខាតគតិយុត្តមួយដ៏មានសារៈសំខាន់ បញ្ចប់និទណ្ឌភាពរបស់នីតិបុគ្គល ដែលបង្កើតបានជាតួអង្គសង្គមសេដ្ឋកិច្ចដ៏មានសារៈសំខាន់ ។

មាត្រា៤២ បានចែងជាគោលការណ៍ថានីតិបុគ្គលលើកលែងតែរដ្ឋចេញ គឺះអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើសដែលប្រព្រឹត្តដោយអង្គការឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលទាំងអស់នោះ ។

មាត្រាដដែលនេះបញ្ជាក់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ពុំត្រូវច្រានចោលនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលចំពោះអំពើដដែលនោះទេ ។

យោងតាមមាត្រានេះ យើងអាចទាញបាននូវលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់នីតិបុគ្គលមានដូចខាងក្រោម៖

### ៣.១.១. នីតិបុគ្គលមិនមែនជារដ្ឋ

ចំពោះនីតិបុគ្គលមិនមែនរដ្ឋ ឬនីតិបុគ្គលឯកជនវិញ ដើម្បីអាចទទួលខុសត្រូវព្រហ្មទណ្ឌ គឺទាល់តែចូលទៅ ក្នុងលក្ខខណ្ឌ ដែលនីតិបុគ្គលនេះបានប្រព្រឹត្តបទល្មើសណាមួយ ដោយធ្វើតាមរយៈតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ[55]។

អត្ថបទច្បាប់នេះ អាចយកទៅអនុវត្តចំពោះគ្រប់នីតិបុគ្គលទាំងអស់ ទោះជាមានសញ្ជាតិខ្មែរ ឬបរទេស ឱ្យតែសកម្មភាពរបស់នីតិបុគ្គលនោះអាចស្ថិតនៅក្រោមច្បាប់ខ្មែរ ដោយអនុលោមតាមវិធានសមត្ថកិច្ចដែលយើងបានសិក្សាកន្លងមកនេះ ។

ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល ជាបទល្មើសឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ[56]។

[55] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤២។

[56] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៨។

គ្រប់នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋត្រូវ ទទួលទោសនៃបទឧក្រិដ្ឋ បានប្រព្រឹត្តបទល្មើសមជ្ឈិមត្រូវទទួលទោសការផ្តន្ទាទោសមជ្ឈិម ហើយប្រព្រឹត្តបទល្មើសលហុ ត្រូវទទួលការផ្តន្ទាទោសលហុ (ដូច្នេះទណ្ឌកម្មគិតពីការប្រព្រឹត្តនៃបទល្មើស)[57]។

ម្យ៉ាងទៀត អត្ថបទច្បាប់នេះ ក៏ពុំបានបែងចែកទៅតាមនីតិបុគ្គលនៃនីតិឯកជន (ក្រុមហ៊ុន សមាគមន៍) ឬនីតិបុគ្គលនៃនីតិសាធារណៈឡើយ លើកលែងតែចំពោះរដ្ឋចេញ ដែលពុំអាចធ្វើបណ្តឹងព្រហ្មទណ្ឌពីរដ្ឋឡើយ ទោះក្នុងករណីណាក៏ដោយ ។

## ៣.១.២. ប្រព្រឹត្តដោយអ្នកតំណាង

នៅក្នុងក្របខ័ណ្ឌនៃការដាក់ឱ្យអនុវត្តនូវការទទួលខុសត្រូវព្រហ្មទណ្ឌ អត្ថបទច្បាប់កំរិតការទទួលខុសត្រូវ របស់នីតិបុគ្គលឱ្យមកនៅត្រឹមករណីបទល្មើសដែលប្រព្រឹត្ត ដើម្បីប្រយោជន៍របស់នីតិបុគ្គលដោយស្ថាប័ន ឬតំណាងរបស់ខ្លួនប៉ុណ្ណោះ ។

នេះបានសេចក្តីថា នីតិបុគ្គលទាំងឡាយពុំទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះគ្រប់បទល្មើសទាំងអស់ដែលអាចប្រព្រឹត្តដោយអ្នកដឹកនាំរបស់ខ្លួនឡើយ ។

នៅក្នុងក្របខ័ណ្ឌនៃការដាក់អោយមានការទទួលខុសត្រូវព្រហ្មទណ្ឌនេះ ត្រូវបានបញ្ជាក់បន្ថែមទៀតថា បទល្មើសពិតជាត្រូវបានប្រព្រឹត្តដោយស្ថាប័ន ឬតំណាងរបស់នីតិបុគ្គលនោះ រាល់សមាជិករបស់នីតិបុគ្គលពុំមានជាចាំបាច់នូវគុណភាពជាស្ថាប័ន ឬតំណាងរបស់នីតិបុគ្គលនោះឡើយ ។

**ឧទាហរណ៍** : នៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មមួយ និយោជិតធម្មតាម្នាក់ ដែលពុំមានអំណាចដឹកនាំអ្វីទាំងអស់ ពុំមានគុណភាពជាស្ថាប័ន ឬតំណាងរបស់នីតិបុគ្គលឡើយ ទោះបីជានិយោជិតនោះប្រព្រឹត្តបទល្មើសដែលបានផ្តល់អត្ថប្រយោជន៍ដល់នីតិបុគ្គលក៏ពិតមែន ក៏និយោជិតនេះពុំអាចទំលាក់ការទទួលខុសត្រូវខាងព្រហ្មទណ្ឌដល់នីតិបុគ្គលបានឡើយ ។

## ៣.១.៣. ដើម្បីផលប្រយោជន៍នីតិបុគ្គល

រាល់ការទទួលខុសត្រូវព្រហ្មទណ្ឌ ទាមទារឲ្យមានការបំពេញលក្ខខណ្ឌបន្ត គឺជាការប្រព្រឹត្តបទល្មើសដើម្បីផលប្រយោជន៍នីតិបុគ្គល មានន័យថាចាំបាច់ណាស់ដែលត្រូវឱ្យនីតិបុគ្គលទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌគឺរាល់បទល្មើសព្រហ្មទណ្ឌទាំងនេះត្រូវបានប្រព្រឹត្ត ដើម្បីប្រយោជន៍របស់ខ្លួនមានន័យថាតាមការពិតនីតិបុគ្គលបានទាញយកនូវផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោលជាសម្ភារៈ ឬតាមផ្លូវចិត្ត ដែលកើតចេញពីបទល្មើស។

[57] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៨។

ប្រសិនបើប្រព្រឹត្តនូវបទល្មើស ចារីស្វែងរកត្រឹមតែតំរូវការបំពេញប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ នីតិបុគ្គលពុំមានការទទួលខុសត្រូវឡើយ ។ ប៉ុន្តែ ប្រសិនបើចារីចង់បំរើប្រយោជន៍របស់នីតិបុគ្គល ក្នុងករណីនេះ លក្ខខណ្ឌដែលនាំឱ្យនីតិបុគ្គលទទួលខុសត្រូវខាងព្រហ្មទណ្ឌត្រូវបានបំពេញហើយ ។

តាមការពិត ព្រោះតែនីតិបុគ្គលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌនូវបទល្មើសដែលត្រូវបានប្រព្រឹត្តដើម្បីជាប្រយោជន៍របស់ខ្លួន ដោយស្ថាប័ន ឬតំណាងរបស់ខ្លួនទាំង នេះមានន័យថាបទល្មើសត្រូវបានប្រព្រឹត្តតាមលក្ខណៈសម្ភារៈដោយរូបវន្តបុគ្គលដែលពិតជាស្ថាប័ន ឬតំណាងរបស់នីតិបុគ្គល ។

**ឧទាហរណ៍ ៖** បទល្មើសអាចត្រូវបានប្រព្រឹត្តដោយប្រធានសមាគមមួយ អ្នកដឹកនាំក្រុមហ៊ុនមួយ។ ដើម្បីជៀសវាងកុំឱ្យការទទួលខុសត្រូវរបស់នីតិបុគ្គល នាំទៅរកនិទណ្ឌភាពចំពោះរូបវន្តបុគ្គល ដែលជាចារីសម្ភារៈនៃបទល្មើស ច្បាប់បញ្ញត្តិថារូបវន្តបុគ្គលក៏នឹងអាចចោទប្រកាន់ពីបទព្រហ្មទណ្ឌផងដែរ ។

### ៣.១.៤. ច្បាប់ចែងជាក់លាក់

មាត្រា៤២ បានចែងថានីតិបុគ្គលទាំងឡាយនឹងត្រូវទទួលខុសត្រូវនៅក្នុងករណីដែលមានចែងដោយច្បាប់និងបទដ្ឋានគតិយុត្តិផ្សេងទៀត។

ដូច្នេះនីតិបុគ្គលត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌនូវបទល្មើសដែលត្រូវបានប្រព្រឹត្ត ដើម្បីជាប្រយោជន៍របស់ខ្លួនបានលុះត្រាតែ "**នៅក្នុងករណីដែលមានចែងដោយច្បាប់**" ប៉ុណ្ណោះ ។

និយាយម្យ៉ាងទៀត ការទទួលខុសត្រូវរបស់នីតិបុគ្គល ពុំមានលក្ខណៈទូទៅឡើយ។ ការទទួលខុសត្រូវនេះអាចកើតមានឡើង លុះត្រាតែមានអត្ថបទច្បាប់ពិសេសប្រកាសអំពីការទទួលខុសត្រូវ ចំពោះការចោទប្រកាន់ជាក់លាក់មួយប៉ុណ្ណោះ ។ នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ កាលបើច្បាប់ឬលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត បានចែងយ៉ាងជាក់ច្បាស់ថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសណាមួយជាកំណត់។ ដូច្នេះ នីតិបុគ្គលអាចត្រូវបានបន្ទោសអំពីបទល្មើសព្រហ្មទណ្ឌមួយ លុះត្រាតែគេត្រូវបានកំណត់ដូចតទៅ ៖

- អត្ថិភាពនៃអត្ថបទច្បាប់ព្រហ្មទណ្ឌពិសេសមួយ ដែលចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ចំពោះបទល្មើសនេះ ។
- បទល្មើសត្រូវបានប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលនោះ ។
- ជាបញ្ចប់ បទល្មើសនេះត្រូវបានប្រព្រឹត្តដោយស្ថាប័ន ឬតំណាងរបស់នីតិបុគ្គលនោះ ។

**ឧទាហរណ៍ ៖** មាត្រា ១៨៧ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌចែងថា នីតិបុគ្គលអាចត្រូវបានប្រកាសឱ្យទទួលខុសត្រូវខាងព្រហ្មទណ្ឌ អំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលត្រូវបានចែងនៅក្នុងមាត្រា ១៨៣ ។

ទាក់ទងនឹងការកំណត់ប្រភេទគតិយុត្តនៃបទល្មើស ដែលត្រូវបានប្រព្រឹត្តដោយនីតិបុគ្គលថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុនោះត្រូវលើកទៅសិក្សាក្នុងបញ្ហាទោសដែលត្រូវទទួលរងដោយរូបវន្តបុគ្គល (មាត្រា ៤៩ ដល់ មាត្រា ៧៧ ) ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ[58]។

ដូចគ្នានេះផងដែរ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់នីតិបុគ្គល ពុំអាចប្រានចោលនូវការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលឡើយ ចំពោះអំពើដដែលនោះ ។

សេចក្តីបញ្ជាក់នេះមានសារៈសំខាន់ណាស់ ។

តាមការពិត ព្រោះតែនីតិបុគ្គល ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌនូវបទល្មើសដែលត្រូវបានប្រព្រឹត្តដើម្បីជាប្រយោជន៍របស់ខ្លួនដោយស្ថាប័ន ឬតំណាងរបស់ខ្លួន មានន័យថាបទល្មើសនោះត្រូវបានប្រព្រឹត្តតាមលក្ខណៈសម្ភារៈដោយរូបវន្តបុគ្គល ដែលពិតជាស្ថាប័ន ឬតំណាងរបស់នីតិបុគ្គល ។

**ឧទាហរណ៍** : បទល្មើសអាចត្រូវបានប្រព្រឹត្តដោយប្រធានសមាគមមួយ អ្នកដឹកនាំក្រុមហ៊ុនមួយ។ ដើម្បីជៀសវាងកុំឱ្យការទទួលខុសត្រូវរបស់នីតិបុគ្គលនាំទៅរកនិទណ្ឌភាពចំពោះរូបវន្តបុគ្គលត្រូវជាចារីសម្ភារៈនៃបទល្មើស ច្បាប់បញ្ញត្តិថារូបវន្តបុគ្គលក៏នឹងអាចចោទប្រកាន់ពីបទព្រហ្មទណ្ឌផងដែរ ។

ការចោទប្រកាន់ទាំងនេះ នឹងកើតមានឡើងប្រឆាំងចំពោះរូបវន្តបុគ្គល ជួនកាលក្នុងឋានៈជាសហចារីនៃបទល្មើស ជួនកាលក្នុងឋានៈជាអ្នកផ្តើមគំនិត ឬជនសមគំនិត ។ ប្រព័ន្ធនេះ គឺប្រាកដជាមានលក្ខណៈចាំបាច់ ។

តាមពិត នៅក្នុងករណីភាគច្រើន បទល្មើសព្រហ្មទណ្ឌគឺជាបទល្មើសដោយចេតនា ។

ប៉ុន្តែ ក្នុងករណីនេះ នីតិបុគ្គលគឺជាសភាវៈប្រឌិតដែលពុំមានចេតនាឡើយ ។

តាមពិត ចេតនាស្ថិតនៅក្នុងរូបវន្តបុគ្គល ដែលតំណាងឱ្យនីតិបុគ្គល ដែលត្រូវសម្រេចអំពីការប្រព្រឹត្តនូវបទល្មើស ។ អាចជៀសវាងនូវនិទណ្ឌភាពរបស់រូបវន្តបុគ្គលជាការប្រសើរមួយ ។

## ៣.២. របបនៃការទទួលខុសត្រូវរបស់នីតិបុគ្គល

យោងតាមស្មារតីនៃក្រមព្រហ្មទណ្ឌ បានកំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលដោយចែងថា នីតិបុគ្គលលើកលែងតែរដ្ឋចេញ គឺអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទល្មើស

[58] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤២ កថាខណ្ឌទី២។

ដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ[59]។ ក្នុងន័យនេះផង ដែរ នីតិបុគ្គលដែលជារដ្ឋ មិនត្រូវបានប្រកាសនូវទោសចំពោះអំពើណាមួយឡើយ។ ប៉ុន្តែនីតិបុគ្គលដែលមិនមែនជារដ្ឋត្រូវទទួលខុសត្រូវចំពោះអំពើណាមួយ ហើយក៏មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។ ទោសដែល នីតិបុគ្គលអាចត្រូវបានប្រកាសមានដូចជា៖

- ទោសពិន័យក្នុងឋានៈជាមូលទោស
- ទោសបន្ថែម។

ដូចគ្នានេះដែរ មានទោសមួយចំនួនពុំអាចយកមកអនុវត្តបានឡើយចំពោះនីតិបុគ្គល ( ឧទាហរណ៍ ទោសជាប់ពន្ធនាគារ ) ទើបទោសទាំងឡាយដែលអាចអនុវត្តបានចំពោះនីតិបុគ្គលត្រូវបានសម្រេចតាម។

ប៉ុន្តែគេអាចរកឃើញការបែងចែកដូចនឹងរូបវន្តបុគ្គលដែរ មានន័យថាមានមូលទោស និងទោសបន្ថែម។

### ៣.២.១. ទោសពិន័យក្នុងឋានៈជាមូលទោស

មូលទោស ដែលត្រូវទទួលរងដោយនីតិបុគ្គល ( មាត្រា ១៦៧ ) គឺមានទោសពិន័យ និងទោសបន្ថែម ដូចដែលមានចែងនៅក្នុងមាត្រា ១៦៨ ។

ទាក់ទងនឹងការពិន័យ នេះគឺជាទោសដែលត្រូវបានកំណត់ដោយទោសប្បញ្ញត្តិ ។ ប្រព័ន្ធផ្សេងៗទៀត ក៏ធ្លាប់បានយល់ផងដែរ ។

**ឧទាហរណ៍**: នៅក្នុងនីតិបារាំង ទោសពិន័យដែលទទួលរងដោយនីតិបុគ្គល គឺជាការពិន័យ ដែលចែងដោយអត្ថបទច្បាប់ ប៉ុន្តែត្រូវគុណនឹងប្រាំ ។

ដូច្នេះ ប្រសិនបើចំពោះបទល្មើសណាមួយ ច្បាប់បានចែងថា ការពិន័យនឹងត្រូវស្មើ ១,០០០,០០០ រៀល គោលការណ៍ គឺថានៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តដោយនីតិបុគ្គល ទោសពិន័យដែលត្រូវទទួលរង គឺត្រូវស្មើនឹង ៥,០០០,០០០ រៀល ។

ម្យ៉ាងទៀត អាចត្រូវបានប្រើប្រាស់ក្នុងឋានៈជាមូលទោសបាន។ ទោសបន្ថែមដែលត្រូវបាននចែងនៅក្នុងមាត្រា ១៦៨។ នេះមានន័យថាទោសទាំងនេះ អាចត្រូវបានប្រកាសព្រមពេលជាមួយគ្នានឹងការពិន័យ ហើយទោសទាំងនេះនឹងត្រូវប្រកាសជាទោសបន្ថែម ប៉ុន្តែទោសទាំងនេះក៏អាចត្រូវបានប្រកាសដោយគ្មានការពិន័យផងដែរ ហើយទោសទាំងនេះក៏ក្លាយជាមូលទោស ។

[59] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤២ កថាខណ្ឌទី១។

### ៣.២.២. ទោសបន្ថែម

ទោសបន្ថែមសម្រាប់នីតិបុគ្គលអាចប្រកាសដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់។ តាមមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមសម្រាប់អនុវត្តលើនីតិបុគ្គលមានដូចតទៅ៖

- ការរំលាយចោល។
- ការដាក់នៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។
- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន។
- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។
- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។
- ការហាមឃាត់ចំពោះឧបករណ៍អាចដួញដូរបាន ក្រៅពីឧបករណ៍អាចដួញដូរ ឬបានដែលកំណត់ដោយធនាគារ។
- ការហាមឃាត់ចំពោះការប្រើប័ណ្ណទូទាត់។
- ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស។
- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណៈជន ឬដែលបានប្រើប្រាស់ដោយសាធារណៈជន ។
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់ ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុក្នុងទីកន្លែង ដែលបទល្មើសបានប្រព្រឹត្ត។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមទូរគមនាគមន៍សោតទស្សន៍[60]។

[60] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា១៦៨។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងសង្គមខ្មែរ ដែលមានចែងនៅក្នុង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមគោលការណ៍ឯកត្តកម្ម បុគ្គលណាមួយដែលបានប្រព្រឹត្តបទល្មើស បុគ្គលនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ បុគ្គលដែលតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនៅពេលប្រព្រឹត្តបទល្មើសរួមមាន រូបវន្តបុគ្គល សំដៅដល់នីតិជន និងអនីតិជន និងចំណែកនីតិបុគ្គល សំដៅដល់នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន។ ប៉ុន្តែការទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈ និងមានកម្រិតខុសគ្នា។ នីតិជនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈធម្មតាទៅតាមច្បាប់ដែលមានចែង តែពេលខ្លះការទទួលខុសត្រូវក៏មានលក្ខណៈបន្ធូរបន្ថយតាមស្ថានភាពនៃជនល្មើស។ នីតិជនក៏អាចនឹងត្រូវបានបន្ធូរបន្ថយទោស ប្រសិនបើជនល្មើសមានភាពវិបល្លាសស្មារតី ឬទទួលរងអានុភាពនៃកម្លាំង ឬការបង្ខំពីជនណាម្នាក់ឲ្យប្រព្រឹត្តអំពើល្មើស។ ចំពោះអនីតិជនត្រូវបានចែងចេញជាពីរប្រភេទ អនីតិជនក្រោម១៤ឆ្នាំ និងអនីតិជនអាយុ ១៤ឆ្នាំឡើងទៅតែក្រោម១៨ឆ្នាំ។ អនីតិជនក្រោម១៤ឆ្នាំ មិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌទេ តែអាណាព្យាបាលដែលតម្រូវឲ្យទទួលខុសត្រូវតែមានលក្ខណៈជាសំណងរដ្ឋប្បវេណី។ ចំណែកអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ តម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌពាក់កណ្តាលនៃអតិប្បរមានៃទោសរបស់នីតិជន។ ករណីចំពោះ នីតិបុគ្គលជាស្ថាប័នដែលបណ្តុំទៅដោយក្រុមមនុស្សដែលធ្វើរួមគ្នា និងមានគោលបំណងតែមួយ។ ដូច្នេះនីតិបុគ្គលត្រូវទទួលខុសត្រូវជាទោសពិន័យ និងអាចត្រូវទទួលទោសបន្ថែមតាមប្រភេទបទល្មើសដែលនីតិបុគ្គលបាប្រព្រឹត្ត។ នៅពេលដែលរូបវន្តបុគ្គល និងនីតិបុគ្គលប្រព្រឹត្តបទល្មើស ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកើតឡើង ចំណែកឯការអនុវត្តទោស ក៏ត្រូវដាក់ចេញតាមប្រភេទនៃទោស ដែលមានចែងដោយក្រមព្រហ្មទណ្ឌ។ ប្រភេទនៃទោសដែលត្រូវចែងក្នុងក្រមព្រហ្មទណ្ឌរួមមានមូលទោស ទោសបន្ថែម និងទោសជំនួស។ មូលទោស ជាទោសមូលដ្ឋាន ដែលយកមកប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានប្រព្រឹត្តបទល្មើស ហើយមូលទោសត្រូវបានចែងជាពីរគឺទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ទោសបន្ថែមឬអនុទោស ជាទោសដែលតុលាការប្រកាសបន្ថែមទៅលើមូលទោសដែលត្រូវបានអនុវត្តលើរូបវន្តបុគ្គល និងនីតិបុគ្គល។ ទោសជំនួសសំដៅលើទោស ដែលជាទោសការងារសហគមន៍ ឬការស្តីបន្ទោស ដែលជំនួសឲ្យមូលទោស។ បើយើងក្រឡេកមើលលើការអនុវត្តទោស និងការដាក់ទោសមានភាពខុសគ្នារវាងរូបវន្តបុគ្គល និងនីតិបុគ្គល។ បន្ថែមលើសពីនេះទៅទៀត ការរំលត់ទោសក៏អាចត្រូវបានកើតឡើងទៅតាមបុគ្គលិកលក្ខណៈរបស់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលបានប្រព្រឹត្តបទល្មើស ឬអំពើផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ។ នីតិបុគ្គលសាធារណៈមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេពីព្រោះតែនីតិបុគ្គល

សាធារណៈស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ។ យើងអាចសន្និដ្ឋានបានថា កាលដែលរូបវន្តបុគ្គល និងនីតិបុគ្គលតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌដោយច្បាប់ពិតជាមានសារៈសំខាន់ធំក្រៃលែងដល់សង្គមជាតិទាំងមូលដូចជាការលុបបំបាត់ កាត់បន្ថយបទល្មើស ការធ្វើឲ្យសង្គមមានសណ្តាប់ធ្នាប់ សុវត្ថិភាព ស្ថិរភាព និងសន្តិភាព។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវសិក្សាកន្លងមក ការមើលឃើញសកម្មភាពនៃការប្រព្រឹត្តបទល្មើសក្នុងសង្គម ជាក់ស្តែងនាពេលបច្ចុប្បន្នយើងខ្ញុំសង្កេតឃើញថាបទល្មើសបានកើតឡើងជារៀងរាល់ថ្ងៃ ហើយស្ថានភាពនៃបទល្មើសមួយចំនួនគឺមានលក្ខណៈកាន់តែកាចសាហាវធ្វើឱ្យប្រជាពលរដ្ឋមានការភ័យខ្លាច។ កាលបើបទល្មើស នៅក្នុងសង្គមមានការកើនឡើង គឺនាំឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទាំងផ្នែកសេដ្ឋកិច្ច ការអប់រំ និងស្ថានភាព ផ្លូវចិត្តរបស់ប្រជាពលរដ្ឋ។

បើនិយាយពីបទល្មើស គឺមានច្រើនដែលចែងក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ពិសេសមួយចំនួនទៀត។ ប៉ុន្តែយើងខ្ញុំនឹងលើកយកតែបទល្មើសដែលបានកើតឡើងច្រើននៅក្នុងសង្គមមកពិភាក្សាតែប៉ុណ្ណោះ។ ដូចជាបទល្មើសលួច បទល្មើសហិង្សា បទល្មើសគ្រោះថ្នាក់ចរាចរណ៍ បទល្មើសរំលោភសេពសន្ថវៈ និងគ្រឿងញៀនជាដើម។ បើយើងមើលទៅលើអត្ថបទច្បាប់ដែលបានចែងមកគឺមានលក្ខណៈប្រសើរស្ទើរតែគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែអ្វីដែលជាបញ្ហា គឺអ្នកអនុវត្តច្បាប់មួយចំនួន គឺការអនុវត្តនៅមានចំណុចខ្វះខាតមិនទាន់បានពេញលេញនៅឡើយទេ។ ដើម្បីធ្វើឱ្យការទទួលខុសត្រូវព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាពនិងយុត្តិធម៌ យើងខ្ញុំមាននូវសំណូមពរចំនួន៣ ៖

សំណូមពរទី១៖ នៅពេលដែលមានបទល្មើសកើតឡើងភ្លាមៗ សូមឱ្យមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធនឹងបទល្មើស ធ្វើការព័ទ្ធរង្វង់នៅកន្លែងកើតហេតុ និងធ្វើការប្រមូលយកភស្តុតាងឱ្យអស់ពីកន្លែងកើតហេតុ ព្រោះតុលាការធ្វើការជំនុំជម្រះដោយផ្អែកទៅលើភស្តុតាង ប្រសិនបើភស្តុតាងមិនគ្រប់ និងនាំឱ្យជនដែលបានប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយសារមតិលសង្ស័យត្រូវបានជាផលប្រយោជន៍ដល់ជនជាប់ចោទ។

សំណូមពរទី២៖ សូមឱ្យមេធាវីដែលការពារក្តីឱ្យជនក្រីក្រ មេត្តាយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើផលប្រយោជន៍របស់កូនក្តី ព្រោះថាប្រសិនបើជនល្មើសបានប្រព្រឹត្តបទល្មើសលួច ហើយព្រះរាជអាជ្ញាចោទពីបទលួចមានស្ថានទម្ងន់ទោស ហើយក្នុងនាមជាមេធាវីមិនបានផ្តល់ការប្រឹក្សាយោបល់ទៅឱ្យកូនក្តីឱ្យបានត្រឹមត្រូវទេ ហើយនាំឱ្យខាតប្រយោជន៍កូនក្តី និងធ្វើឱ្យទណ្ឌិតដែលចេញមកវិញនៅតែប្រព្រឹត្តបទល្មើសដដែលហើយអាចសាហាវជាងមុនទៀត។

សំណូមពរទី៣៖ សូមឱ្យនីតិករធ្វើការពិចារណាឡើងវិញពាក់ព័ន្ធទៅនឹងការផ្តន្ទាទោសលើអនីតិជនដែលប្រព្រឹត្តបទល្មើស ដោយសារតែអនីតិជន គឺមានច្បាប់ការពារជាច្រើនទាំងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន តែយើងខ្ញុំសង្កេតឃើញនៅក្នុងសង្គមជាក់ស្តែង អនីតិជនពេលខ្លះអាចប្រព្រឹត្តបទល្មើស

ធ្ងន់ធ្ងរជាង នីតិជនទៀតផង ដូចជាបទល្មើសហិង្សា បទលួចហើយរំលោភសេពសន្ថវៈ ពេលដែលប្រព្រឹត្តហើយបង្កជាព្យសនកម្មយ៉ាងខ្លាំងដល់ជនរងគ្រោះ។ ដោយសារតែមានច្បាប់ការពារ ការផ្តន្ទាទោសទៅអនីតិជនមានលក្ខណៈស្រាលជាងដល់ទៅពាក់កណ្តាល ពេលដែលគាត់ចេញមកអាចនឹងប្រព្រឹត្តបទល្មើសសារជាថ្មី។

# ឯកសារយោង

# ឯកសារយោង

- បទដ្ឋានគតិយុត្ត
  - រដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣
  - ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ៣០ វិច្ឆិកា ២០០៩
  - ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ១០ សីហា ២០០៧
  - ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧
- ឯកសារជាសៀវភៅ និងឯកសារផ្សេងៗទៀត
  - សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ របស់សាស្ត្រាចារ្យ កៅ សីហា ឆ្នាំ២០១៣
  - សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌរបស់ទីស្ដីការគណៈរដ្ឋមន្ត្រីឆ្នាំ ២០១១
  - សន្ទានុក្រមពាក្យច្បាប់ ផ្នែករដ្ឋប្បវេណី និងនីតិរដ្ឋប្បវេណីរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
  - គោលការណ៍សច្ចាធារណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា
  - អនុសញ្ញាស្ដីពីសិទ្ធិកុមារ
  - ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១: អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម

ឧបសម្ព័ន្ធទី២: ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី៣: ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី៤: ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

ឧបសម្ព័ន្ធទី៥: សាលក្រម

# ឧបសម្ព័ន្ធទី១

# អនុសញ្ញាស្តីពីសិទ្ធិកុមារ

## និង

# ពិធីសារបន្ថែម

៤. បើការរស់នៅបែកគ្នាបណ្ដាលមកពីវិធានការណាមួយផ្ដើមដោយរដ្ឋភាគី មានជាអាទិ៍ការឃាត់ឬការឃុំខ្លួន ការដាក់ពន្ធនាគារ ការនិរទេស ការបំបរបង់ ឬមរណភាព (រួមទាំងមរណភាពបណ្ដាលមកពីបុព្វហេតុណាមួយក្នុងខណៈពេលដែលបុគ្គលនោះ ត្រូវបានឃាត់ ឬឃុំខ្លួនដោយរដ្ឋ) ឪពុក ឬម្ដាយ ឬឪពុក-ម្ដាយទាំងពីរ ឬកុមារ នោះរដ្ឋភាគី ដោយយោងតាមការស្នើសុំ ត្រូវជូនដំណឹងទៅឪពុក-ម្ដាយ ឬកុមារ ឬបើសមស្រប ត្រូវជូនដំណឹងទៅសមាជិកគ្រួសារណាម្នាក់ផ្សេងទៀតនូវព័ត៌មានសំខាន់អំពីទីកន្លែងនៃសមាជិកគ្រួសារណាម្នាក់ ឬច្រើននាក់ដែលអវត្តមាន លើកលែងតែការជូនដំណឹងនេះ ប៉ះពាល់ដល់ផាសុខភាពរបស់កុមារ។ ម្យ៉ាងទៀត រដ្ឋភាគីត្រូវធានាថាការដាក់សេចក្ដីស្នើសុំមួយបែបនេះ នឹងមិននាំឱ្យមានផលជាអវិជ្ជមានសម្រាប់បុគ្គលពាក់ព័ន្ធឡើយ។

## មាត្រា ១០

១. ស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ គ្រប់សេចក្ដីស្នើសុំរបស់កុមារ ឬឪពុក ឬម្ដាយរបស់កុមារ ដើម្បីចូល ឬចាកចេញពីរដ្ឋភាគី ក្នុងគោលបំណងជួបជុំគ្រួសារ ត្រូវតែដោះស្រាយក្នុងស្មារតីវិជ្ជមាន មនុស្សធម៌ និងឱ្យបានឆាប់រហ័ស។ ក្រៅពីនេះ រដ្ឋភាគីត្រូវធានាថា ការដាក់សេចក្ដីស្នើសុំនេះ នឹងមិនបង្កឱ្យមានផលអវិជ្ជមានដល់អ្នកសុំ និងដល់សមាជិកគ្រួសាររបស់អ្នកសុំឡើយ ។

២. កុមារដែលមានឪពុក-ម្ដាយរស់នៅក្នុងរដ្ឋផ្សេង មានសិទ្ធិរក្សាជាទៀងទាត់នូវទំនាក់ទំនងផ្ទាល់ និងការទាក់ទងដោយផ្ទាល់ ជាមួយឪពុក-ម្ដាយទាំងពីរ លើកលែងតែក្នុងកាលៈទេសៈពិសេស។ ក្នុងទិសដៅនេះ និងស្របតាមកាតព្វកិច្ចរបស់រដ្ឋភាគី ក្រោមមាត្រា៩ កថាខណ្ឌ១ រដ្ឋភាគី ត្រូវគោរពសិទ្ធិរបស់កុមារ និងសិទ្ធិឪពុក-ម្ដាយរបស់កុមារ ក្នុងការចាកចេញពីប្រទេស រួមមាន ប្រទេសរបស់ខ្លួនផង និងវិលចូលមកក្នុងប្រទេសរបស់ខ្លួនវិញ។ សិទ្ធិចាកចេញពីប្រទេសណាមួយ អាចស្ថិតក្រោមការរិតត្បិតបាន លុះត្រាតែការរិតត្បិតនោះ បញ្ញត្តិដោយច្បាប់ និងចាំបាច់ដើម្បីការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ហើយស្របនឹងសិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយអនុសញ្ញានេះ។

## មាត្រា ១១

១. រដ្ឋភាគី ត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការផ្ទេរកុមារចេញក្រៅប្រទេស ដោយខុសច្បាប់ និងការមិនប្រគល់កុមារពីក្រៅប្រទេសមកវិញ។

# ឧបសម្ព័ន្ធទី២

# ក្រម

# ព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុង ដូចតទៅនេះ :

**មាត្រា ១៥.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬ ឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៦.–** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៧.–** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះ ត្រូវបានបំពេញ :

-បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៨.–** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២
## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.–** បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

LE MINISTRE DU PALAIS ROYAL

**មាត្រា ២៣.-** ការមិនចោទប្រកាន់ក្រោយក្តី និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀង ប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-បើមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ អាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្ដើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្ដន្ទាទោសទេ ។

**មាត្រា ២៨.-** និយមន័យនៃអ្នកផ្ដើមគំនិត

ត្រូវចាត់ទុកជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែល :

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ តាមការណែនាំ ឬ ការបញ្ជា ។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការល្បួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ២៩.-** និយមន័យនៃអ្នកសមគំនិត

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្ដល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន ។

អ្នកសមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ៣០.-** និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត

១-អ្នករាជការសាធារណៈ មានន័យថា :

ក/ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិបញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬ មិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណ៍នៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍ នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

ROYAUME DU CAMBODGE ... ក្រសួងព្រះបរមរាជវាំង ... MINISTERE DU PALAIS ROYAL



Ksl

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬ ការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធាន-ការការពារ និងវិធានការឧបត្ថម្ភ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈ របស់អនីតិជន ពម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមាន ដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលម្នាក់ដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលដទៃក្រៅពីរដ្ឋ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទ-

ROYAUME DU CAMBODGE · SECRÉTARIAT DU PALAIS ROYAL



Ksl

ល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍ របស់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ក្នុងអំពើដដែលនោះទេ ។

## មាតិកាទី ៣

## ទោស

## ជំពូកទី ១

## ប្រភេទនៃទោស

### ផ្នែកទី ១

### មូលទោស

**មាត្រា ៤៣.-** មូលទោស

មូលទោសរួមមាន ទោសដាក់ពន្ធនាគារ និងទោសពិន័យ ។

ការពិន័យត្រូវគិតជាប្រាក់រៀល ។

**មាត្រា ៤៤.-** អប្បបរមា និងអតិបរមានៃមូលទោស

កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ ។

កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល ។

**មាត្រា ៤៥.-** ការទម្ងន់ទោស និងការសម្រាលទោស

អប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ និងការពិន័យជាប្រាក់ អាចបន្ថែម ឬ បន្ថយនៅក្នុងលក្ខខណ្ឌដែលចែងដោយក្រមនេះ ។

**មាត្រា ៤៦.-** និយមន័យនៃបទឧក្រិដ្ឋ

បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១-ជាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ និងក្រោម ឬ ស្មើនឹង ៣០ (សាមសិប) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៧.-** និយមន័យនៃបទមជ្ឈិម

បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥ (ប្រាំ) ឆ្នាំ ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

**មាត្រា ៤៨.-** និយមន័យនៃបទលហុ

បទល្មើសជាបទលហុ នៅក្នុងករណីដែល :

១-អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬ ស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ ។

២-បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ៤៩.-** ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ ១ (មួយ) ថ្ងៃ ត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ខែ ត្រូវគិតតាមចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ ។

ទោសដាក់ពន្ធនាគារ ១ (មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ ។

**មាត្រា ៥០.-** លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស

ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឱ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ ។

**មាត្រា ៥១.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការល្បួរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

១៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

១៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

១៥-ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស ។

១៦-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ។

១៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ។

១៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែក អាចបង្កើតទោសបន្ថែមផ្សេងៗទៀត ។

**មាត្រា ៥៤.-** លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម

ទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ដែលត្រូវចោទប្រកាន់ ។

ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន ។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់ ។

**មាត្រា ៥៥.-** សិទ្ធិពលរដ្ឋដែលអាចដកបាន

សិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៣(ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ រួមមាន :

១-សិទ្ធិបោះឆ្នោត ។

២-សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ។

៣-សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ។

៤-សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬ ជាអាណត្តិគាហករបស់តុលាការ ។

៥-សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់ ។

៦-សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ ។

**មាត្រា ៧១.-** ពេលនៃការអនុវត្តទោសបន្ថែម

ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ នៃមាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ ត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។

## ផ្នែកទី ៣

## ទោសជំនួស

### កថាភាគទី ១

### ការងារសហគមន៍

**មាត្រា ៧២.-** និយមន័យនៃការងារសហគមន៍

កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍ ។

ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោង ទៅ ២០០ (ពីររយ) ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ នីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬ ដល់អង្គការមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧៣.-** អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍

នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍នៃឯកជន-បុគ្គលទេ ។

**មាត្រា ៧៤.-** របបគតិយុត្តនៃការងារសហគមន៍

ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

**មាត្រា ៧៥.-** គោលការណ៍ផ្តល់សំណងការខូចខាតដល់អ្នកដទៃ

រដ្ឋត្រូវតែចេញសោហ៊ុយផ្តល់សំណងការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុងអនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់

ទៅក្នុងសិទ្ធិជនរងគ្រោះ ។

## កថាភាគទី ២
## ការស្តីបន្ទោស

**មាត្រា ៧៦.-** របបគតិយុត្តនៃការស្តីបន្ទោស

កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬ ស្មើនឹង ៣ (បី) ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌ ទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ ។

## ជំពូកទី ២
## ស្ថានទម្ងន់ទោស និងស្ថានសម្រាលទោស
## ផ្នែកទី ១
## ស្ថានទម្ងន់ទោស
## កថាភាគទី ១
## និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ

**មាត្រា ៧៧.-** ក្រុមមានការចាត់តាំង

ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬ ជាសន្ធិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬ ប្រព្រឹត្តបទល្មើសមួយ ឬ ច្រើន ។

**មាត្រា ៧៨.-** ការគិតទុកជាមុន

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាពប្រព្រឹត្តបទល្មើស ។

**មាត្រា ៧៩.-** ការបាក់គាស់ទម្លុះទម្លាយ

ការបាក់គាស់ទម្លុះទម្លាយគឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬ បំផ្លិចបំផ្លាញគ្រឿងបិទទ្វារ

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ២ (ពីរ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ (ប្រាំ) ឆ្នាំ ហើយតិចជាង ១០ (ដប់) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ) ឆ្នាំ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ២ (ពីរ) ឆ្នាំ ហើយតិចជាង ៥ (ប្រាំ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ ហើយតិចជាង ២ (ពីរ) ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យ ត្រូវបន្ថយមកត្រឹមពាក់កណ្ដាល ។

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស

កាលណាបទល្មើសត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្ដល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះរវាង ១៥ (ដប់ប្រាំ) និង ៣០ (សាមសិប) ឆ្នាំ ។

## ជំពូកទី ៣

## របបនៃការប្រកាសទោស

### ផ្នែកទី ១

### របបទូទៅ

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស

តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ ។

**មាត្រា ៩៧.-** ការប្រកាសមូលទោស

ក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារផង និង ពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស

ទោសការងារសហគមន៍ជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសទោស ការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ ។

ការស្តីបន្ទោសជំនួសឱ្យមូលទោស ។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់បានទេ ។

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស

កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬ ច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសដោយទោសបន្ថែម) នៃក្រមនេះចេញ ។

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម

តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬ ច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់ ។

២-កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬ តិចជាង ៣ (បី) ឆ្នាំ ។

កាលណាតុលាការសម្រេចជំនួសមូលទោសដោយទោសបន្ថែមមួយ ឬ ច្រើន តុលាការមិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬ ទោសពិន័យជាប្រាក់បានទេ ។

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍

ទោសការងារសហគមន៍នឹងអាចប្រកាសបាន លុះត្រាតែជនជាប់ចោទមានវត្តមាននៅក្នុងពន្ធនាគារ ហើយយល់ព្រមធ្វើការងារនេះ ។ តុលាការនៅមុនពេលប្រកាសសាល

## ជំពូកទី ៥
## មូលហេតុនានាដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស
### ផ្នែកទី ១
### អាជ្ញាយុកាលនៃទោស

**មាត្រា ១៤២.–** អានុភាពនៃអាជ្ញាយុកាល

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

**មាត្រា ១៤៣.–** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន

ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៤៤.–** អាជ្ញាយុកាលនៃទោស

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ។

**មាត្រា ១៤៥.–** ចំណុចចាប់ផ្តើមនៃថិរវេលា

ថិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើ ដែលមានចែងនៅក្នុងមាត្រា ១៤៤ (អាជ្ញាយុកាលនៃទោស) នៃក្រមនេះ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោស បានក្លាយទៅជាស្ថាពរ ។

**មាត្រា ១៤៦.–** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្តីសម្រេចព្រហ្មទណ្ឌ

កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណី និងដែលមានប្រភពចេញមកពីសេចក្តីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។

១-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

២-ការបិទគ្រឹះស្ថាន ។

៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហ ដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ។

## ជំពូកទី ៦

## ទោសដែលអាចអនុវត្តចំពោះអនីតិជន

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬ តិចជាង ៥ (ប្រាំ)ឆ្នាំ នោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ)ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះ-បណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៦ (ប្រាំមួយ) ខែ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬ ព្យាបាល ។

៤-ជួសជុលព្យសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយតាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

## ផ្នែកទី ២
## បទបញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ៧
## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.–** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

### ផ្នែកទី ២
### ទោសបន្ថែម

**មាត្រា ១៦៨.–** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់អតិថិជន ឬ ដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្ត

បទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.–** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.–** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្ដីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.–** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំទេ ។ សេចក្ដីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។ ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្ដឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្ដាប់យោបល់របស់[illegible]ព្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

(បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាឃាតកម្ម ។

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២០០.-** បទឃាតកម្មគិតទុកជាមុន

ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការលួចស្ទាក់ ។

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើលៀតលៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។

ការលួចស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើលៀតលៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។

ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ២០១.-** បទឃាតកម្មដោយការប្រើថ្នាំពុល

ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ២០២.-** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៤-អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ការប៉ះពាល់ដោយអចេតនាដល់ជីវិតមនុស្ស

**មាត្រា ២០៧.-** បទមនុស្សឃាតដោយអចេតនា

បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឱ្យស្លាប់អ្នកដទៃដោយ :

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជា ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២០៨.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសចំពោះបទមនុស្សឃាតដោយអចេតនា :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ២

## ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល

### ផ្នែកទី ១

### ទារុណកម្ម និងអំពើឃោរឃៅ

**មាត្រា ២១០.-** បទទារុណកម្ម និងអំពើឃោរឃៅ

ទារុណកម្ម ឬអំពើឃោរឃៅដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២១១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើស

ត ទៅរាជកិច្ចលេខ ២

**មាត្រា ២២៤.–** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ២២៥.–** ការចាត់ទុកការប្រើសារជាតិពុលដូចជាអំពើហិង្សាដោយចេតនា

អំពើដែលឱ្យអ្នកដទៃផឹក លេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាក៏ដោយ ដោយចេតនានូវសារជាតិពុលដែលបណ្តាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៦.–** ការចាត់ទុកការផ្តល់អាហារដែលមានសារជាតិពុល ដូចជាអំពើហិង្សាដោយចេតនា

អំពើលក់ ធ្វើអនុប្បទាន ឬ ឱ្យចំណី ឬ ភេសជ្ជៈ ដោយដឹងថាចំណី ឬ ភេសជ្ជៈនោះមានសារជាតិពុលនាំឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៧.–** ការចាត់ទុកការបញ្ចូលសារជាតិពុលក្នុងទឹកសម្រាប់បរិភោគដូចជាអំពើហិង្សាដោយចេតនា

អំពើប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារជាតិពុលនាំឱ្យខូចសុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៨.–** បទហិង្សាស្រាល

អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឱ្យមានរបួសទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ២២៩.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្ត

## ផ្នែកទី ៣
## ការគំរាមកំហែង

**មាត្រា ២៣១.-** បទគំរាមកំហែង

អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ២៣២.-** បទគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងក្រោមទម្រង់ណាក៏ដោយ ថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រឆាំងនឹងបុគ្គល ប្រសិនបើការគំរាមកំហែងនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំនិងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៣.-** បទគំរាមកំហែងថានឹងសម្លាប់

ការគំរាមកំហែងថានឹងសម្លាប់ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយ ម្តងទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៤.-** បទគំរាមកំហែងថានឹងសម្លាប់ ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងថានឹងសម្លាប់ក្រោមទម្រង់ណាក៏ដោយ ប្រសិនបើការគំរាមកំហែងនេះ ត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង 25/2011

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ៣
## ការបំពានខាងផ្លូវភេទ
### ផ្នែកទី ១
### ការរំលោភសេពសន្ថវៈ

**មាត្រា ២៣៩.-** បទរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆ្លក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់)

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤០.–** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើង :

១-ដោយការប្រើអាវុធ ឬ គំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬ គ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬ ចុះខ្សោយលទ្ធភាពទប់ទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

**មាត្រា ២៤១.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២៤២.–** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព

- បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២៤៣.–** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០(សាមសិប) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើ

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើស បានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២៤៩.–** បទបង្ហាញកេរភេទ

អំពើបង្ហាញកេរភេទដែលនាំឱ្យអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែលសាធារណជនអាចមើលឃើញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ២៥០.–** បទរុករកខាងផ្លូវភេទ

អំពើរុករកខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ ។

អំពើរុករកខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ២៥១.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៥២.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាង

ROYAUME DU CAMBODGE ... PALAIS ROYAL

សោកទស្សន៍ សម្រាប់រយៈពេល ៩ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការប៉ះពាល់ដល់សេរីភាពជនផ្សេងៗ

**មាត្រា ២៥៦.-** បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន

អំពើដណ្តើមយក ឬ ត្រួតត្រាលើមធ្យោបាយដឹកជញ្ជូនដែលមានបុគ្គលច្រើនរូបជិះក្នុងនោះ ដោយហិង្សា ឬ ដោយការគំរាមកំហែងថានឹងប្រើហិង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ២៥៧.-** ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬ ពិការភាព

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើបទល្មើសនោះនាំឱ្យមានការកាត់អវយវៈ ឬ ឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២៥៨.-** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើមានធ្វើទារុណកម្ម ឬ អំពើឃោរឃៅ នៅមុនពេល ក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តបទល្មើស ។

**មាត្រា ២៥៩.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើបទល្មើសនេះបណ្តាលឱ្យមនុស្សស្លាប់ម្នាក់ ឬ ច្រើននាក់ ។

**មាត្រា ២៦០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

១-ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

ROYAUME DU CAMBODGE · SECRETARIAT DU PALAIS ROYAL
85/2014



ksl

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ៦

## ការប៉ះពាល់ផ្សេងទៀតដល់សេចក្តីថ្លៃថ្នូរ

**មាត្រា ២៩៧.-** បទស្រវឹងជាក់ស្តែង

បុគ្គលណាដែលស្ថិតនៅក្នុងសភាពស្រវឹងយ៉ាងជាក់ស្តែងនៅលើផ្លូវសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ២៩៨.-** បទហៅអ្នកដទៃនៅទីសាធារណៈ

បុគ្គលណាដែលហៅអ្នកដទៃនៅទីសាធារណៈ ដើម្បីញុំាងឱ្យមានទំនាក់ទំនងផ្លូវភេទ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ៥០.០០០ (ប្រាំម៉ឺន) រៀល ។

## ជំពូកទី ៦

## ការប៉ះពាល់ដល់បុគ្គលភាព

## ផ្នែកទី ១

## ការប៉ះពាល់ដល់ជីវភាពឯកជន

**មាត្រា ២៩៩.-** បទរំលោភលើលំនៅឋាន

អំពើប្រព្រឹត្តដោយមានហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ឧបាយកលចូលទៅក្នុងលំនៅឋានអ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

**មាត្រា ៣០០.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជាតិ

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬ ក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ចូលទៅក្នុងលំនៅឋានរបស់អ្នកដទៃដោយគ្មានការយល់ព្រម

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបរិហារកេរ្តិ៍ និងការជេរប្រមាថ

**មាត្រា ៣០៥.-** បទបរិហារកេរ្តិ៍ជាសាធារណៈ

គ្រប់ការអះអាងបំផ្លើស ឬ ការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ កិត្តិស័ព្ទនៃបុគ្គល ឬ នៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បទបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយ ដូចតទៅ :

១-តាមសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ ។

២-តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬ ដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៣០៦.-** អំពើបរិហារកេរ្តិ៍តាមសារព័ត៌មាន

ការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៧.-** បទជេរប្រមាថជាសាធារណៈ

គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬ គ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បទជេរប្រមាថដែលប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយដូចតទៅ :

១-តាមពាក្យសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ ។

២-តាមលិខិត ឬ គំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬ ដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៣០៨.—** អំពើជេរប្រមាថតាមសារព័ត៌មាន

ការជេរប្រមាថដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៩.—** នីតិវិធីបណ្តឹងចំពោះបទបរិហារកេរ្តិ៍ និងបទជេរប្រមាថ

ក្នុងករណីដែលមានការបរិហារកេរ្តិ៍ ឬ ការជេរប្រមាថ ចំពោះសមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការសាធារណៈ ឬ ពលរដ្ឋដែលទទួលបន្ទុកបេសកកម្មសាធារណៈ ឬ អាណត្តិសាធារណៈ ការចោទប្រកាន់នឹងត្រូវធ្វើឡើងតាមបណ្តឹងរបស់សាមីខ្លួន ឬ បណ្តឹងរបស់ប្រធានស្ថាប័នសាមី ។

ក្នុងករណីដែលមានការបរិហារកេរ្តិ៍ ឬ ការជេរប្រមាថ ចំពោះបុគ្គលឯកជន ការចោទប្រកាន់នឹងត្រូវធ្វើឡើងតាមបណ្តឹងរបស់សាមីខ្លួនដែលទទួលរងនូវការបរិហារកេរ្តិ៍ ឬ ការជេរប្រមាថនោះ ។

ពាក្យប្តឹងរបស់សាមីខ្លួន ឬ ប្រធានស្ថាប័នសាមី ដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ គឺជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយអយ្យការ ហើយការដកពាក្យប្តឹងវិញរបស់អ្នកប្តឹង នាំឱ្យបណ្តឹងអាជ្ញារលត់។

ក៏ប៉ុន្តែ ការចោទប្រកាន់អាចនឹងត្រូវធ្វើឡើងដោយស្វ័យប្រវត្តដោយព្រះរាជអាជ្ញា កាលបើការបរិហារកេរ្តិ៍ ឬ ជេរប្រមាថនោះ ត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលម្នាក់ ឬ បុគ្គលមួយក្រុម ដោយមូលហេតុដើមកំណើត ជាតិពន្ធុ ពូជសាសន៍ សញ្ជាតិ ឬ សាសនារបស់

៣-ដោយបុគ្គលច្រើនរូប ដែលធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

៤-ដោយការបង់លាភការ ។

## ផ្នែកទី ២

## ការញុះញង់អនីតិជនឱ្យប្រព្រឹត្តអំពើខុសច្បាប់ ឬអំពើគ្រោះថ្នាក់

**មាត្រា ៣៤៣.-** បទញុះញង់អនីតិជនឱ្យបរិភោគគ្រឿងស្រវឹង

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យបរិភោគជាប្រចាំ និងយ៉ាងច្រើននូវគ្រឿងស្រវឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៣៤៤.-** បទញុះញង់អនីតិជនឱ្យសុំទាន

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យសុំទាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣៤៥.-** បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤៦.-** បទរៀបចំបង្ហាញភេទ ឬ ទំនាក់ទំនងខាងផ្លូវភេទដោយមានការចូលរួមរបស់អនីតិជន

អំពើរបស់នីតិជនដែលរៀបចំការជួបជុំ ដែលរួមមានការបង្ហាញភេទ ឬ មានទំនាក់ទំនងខាងផ្លូវភេទ ដោយមានអនីតិជនបានមើល ឬ ចូលរួមផងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL

## គន្ថីទី ៣

## បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ

## មាតិកាទី ១

## ការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត

## ជំពូកទី ១

## ការលួច និងបទល្មើសប្រហាក់ប្រហែល

## ផ្នែកទី ១

## ការលួច

**មាត្រា ៣៥៣.–** និយមន័យនៃអំពើលួច

អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**មាត្រា ៣៥៤.–** អំពើលួចថាមពល

ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ ។

**មាត្រា ៣៥៥.–** អភ័យឯកសិទ្ធិគ្រួសារ

មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបានទេ :

១-អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ ។

២-អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ ។

**មាត្រា ៣៥៦.–** ទោសដែលត្រូវអនុវត្ត

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៥៧.–** ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណី

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ឧបឃាត និងការរួមគំនិតក្បត់

**មាត្រា ៤៥១.-** បទឧបឃាត

ឧបឃាត គឺជាការប្រព្រឹត្តអំពើហិង្សាមួយ ឬ ច្រើន ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬ នាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ។

បទឧបឃាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៥២.-** ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនល្មើស

ឧបឃាតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយភ្នាក់ងារសាធារណៈ ។

# ឧបសម្ព័ន្ធទី៣

# ក្រមនីតិវិធីព្រហ្មទណ្ឌ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

34/2407K

៥-អាជ្ញាអស់ជំនុំ ។

កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬ ត្រូវតែបញ្ឈប់ ។

**មាត្រា ៨.–** មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា

កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរ :

១-ដោយការសម្របសម្រួលជាមួយរដ្ឋ ។

២-ដោយការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។

៣-ដោយការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល ។

**មាត្រា ៩.–** ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់

បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតអាជ្ញាយុកាលបានទេ ។

**មាត្រា ១០.–** អាជ្ញាយុកាលនៃបទល្មើស

លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ៩ (ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់) នៃក្រមនេះចេញ ថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺ :

-១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម

-១ (មួយ) ឆ្នាំ ចំពោះបទលហុ

**មាត្រា ១១.–** ការផ្តាច់រយៈពេលនៃអាជ្ញាយុកាល

ថិរវេលានៃអាជ្ញាយុកាល ត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស ។ អាជ្ញាយុកាលត្រូវផ្តាច់ ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬ កិច្ចស៊ើបសួរ ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬ កិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល តាមការវែកញែកនៃមាត្រា ១០ (អាជ្ញាយុកាលនៃបទល្មើស) នៃក្រមនេះ ។ ថិរវេលាថ្មីអាចយកទៅជំទាស់បាន ចំពោះជនគ្រប់រូបដែលទាក់ទិននៅក្នុងរឿងនេះ ។

## ផ្នែកទី ២

## សមត្ថកិច្ចសម្ភារៈ និងសមត្ថកិច្ចដែនដី

**មាត្រា ២៨៩.–** សមត្ថកិច្ចរបស់សាលាដំបូង

សាលាដំបូងជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ។ សាលាដំបូងសម្រេចជាក្រុមសម្ភហភាពដែលមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង ។

សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទមជ្ឈិម និងបទលហុ ។

**មាត្រា ២៩០.–** វិវាទសមត្ថកិច្ចរវាងសាលាដំបូង

តុលាការដែលមានសមត្ថកិច្ចខាងដែនដីគឺ :

- តុលាការនាទីកន្លែងបទល្មើស
- តុលាការនាលំនៅឋានរបស់ជនជាប់ចោទ ឬ
- តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ ។

ក្នុងករណីដែលមានតុលាការពីរ ឬ ច្រើន ដែលស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួលពាក្យប្ដឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង ។

វិវាទសមត្ថកិច្ចដែនដី រវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នា ត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់ ។

ការសម្រេចនេះបិទផ្លូវតវ៉ា ។

សមត្ថកិច្ចចំពោះជនជាប់ចោទត្រូវពន្លាតរហូតដល់សហចារី អ្នកផ្ដើមគំនិត និងអ្នកសមគំនិតទាំងអស់ ។

ប្រសិនបើតុលាការដែលបានទទួលពាក្យប្ដឹងយល់ឃើញថាពុំមានសមត្ថកិច្ចតាមដែនដី តុលាការនេះប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រម និងបង្គាប់ឱ្យបញ្ជូលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះ ជូនតុលាការដែលមានសមត្ថកិច្ចតាមដែនដី ។ ជាយថាហេតុ តុលាការនេះសម្រេចសេចក្ដីលើការបន្តដាក់ជនជាប់ចោទឱ្យស្ថិតក្នុងការឃុំខ្លួន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ ។

139/240

# ឧបសម្ព័ន្ធទី៤

# ច្បាប់

# ស្តីពី

# ការត្រួតពិនិត្យគ្រឿងញៀន




២/៧៩

# ព្រះរាជក្រម

នស/រកម/០១១២/០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចមាន ខាងក្រោមនេះ :

១- បើការផលិតជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រោមឡើងទៅ ។

២- បើការផលិតប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រោម ឡើងទៅ ។

៣- បើការផលិតម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រោមឡើងទៅ ។

៤- បើការផលិតអំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រោមឡើងទៅ ។

៥- បើការផលិតបណ្តាសារធាតុញៀនផ្សេងទៀតដែលស្ថិតនៅក្នុងតារាងទី ១ និងតារាង ទី ២ មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រោមឡើងទៅ ។

៦- បើការផលិតសារធាតុញៀនចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុប នៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី ១ ដល់ចំណុចទី ៥ នៃកថាខណ្ឌនេះ ។

**មាត្រា ៤០.- បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**

ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវ សារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។

ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឲ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ពី មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀន ជាអាទិ៍ តាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ គឺជាអំពើដឹកជញ្ជូនដោយខុសច្បាប់នូវ សារធាតុញៀន ។

ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារ-ធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និ[illegible] ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់

ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

៣- ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៤០០ (បួនរយ) ក្រាម រហូតដល់ក្រោម ៨០០ (ប្រាំបីរយ) ក្រាម ។

៤- ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ២០០ (ពីររយ) ក្រាម រហូតដល់ក្រោម ៤០០ (បួនរយ) ក្រាម ។

៥- ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ៤ (បួន) ក្រាម រហូតដល់ក្រោម ២៥ (ម្ភៃប្រាំ)ក្រាម។

៦- អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

៧- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៨ (ប្រាំបី) គីឡូក្រាម រហូតដល់ក្រោម ២០ (ម្ភៃ) គីឡូក្រាម ។

៨- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៨ (ប្រាំបី) គីឡូក្រាម រហូតដល់ក្រោម ៤០ (សែសិប) គីឡូក្រាម ។

៩- ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ៤០ (សែសិប) គីឡូក្រាម រហូតដល់ក្រោម ១៦០ (មួយរយ ហុកសិប) គីឡូក្រាម ។

១០- បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

១១- សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី ៣ ដល់ចំណុចទី ១០ នៃកថាខណ្ឌនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២៣/៧៩

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- ជ័រអាភៀន ជ័រកញ្ឆា ឬកាវកូកា មានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រាម រហូតដល់ក្រាម ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រាម ។

២- ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤០០ (បួនរយ) ក្រាម រហូតដល់ក្រាម ៨០០ (ប្រាំបីរយ) ក្រាម ។

៣- ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ២៥ (ម្ភៃប្រាំ) ក្រាម រហូតដល់ក្រាម ៨០ (ប៉ែតសិប) ក្រាម ។

៤- អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រាម ២៤០ (ពីររយសែសិប) ក្រាម ។

៥- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ២០ (ម្ភៃ) គីឡូក្រាម រហូតដល់ក្រាម ៦០ (ហុកសិប) គីឡូក្រាម ។

៦- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៤០ (សែសិប) គីឡូក្រាម រហូតដល់ក្រាម ១២០ (មួយរយម្ភៃ) គីឡូក្រាម ។

៧- ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ១៦០ (មួយរយហុកសិប) គីឡូក្រាម រហូតដល់ក្រាម ៤៨០ (បួនរយប៉ែតសិប) គីឡូក្រាម ។

៨- បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រាម ២៤០ (ពីររយសែសិប) ក្រាម ។

៩- សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី ១ ដល់ចំណុចទី ៨ នៃកថាខណ្ឌនេះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :



១- ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធ ចាប់ពី ១.៦០០ ( មួយពាន់ប្រាំមួយរយ ) ក្រាម ឡើងទៅ ។

២- ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៨០០ ( ប្រាំបីរយ ) ក្រាម ឡើងទៅ ។

៣- ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធ ចាប់ពី ៨០ (ប៉ែតសិប) ក្រាម ឡើងទៅ ។

៤- អំហ្វេតាមីន មេតំហ្វេតាមីន ឬអិចស្តាស៊ីមានបរិមាណសុទ្ធ ចាប់ពី ២៤០ ( ពីររយសែសិប ) ក្រាម ឡើងទៅ ។

៥- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៦០ (ហុកសិប) គីឡូក្រាម ឡើងទៅ ។

៦- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ១២០ (មួយរយម្ភៃ) គីឡូក្រាម ឡើងទៅ ។

៧- ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ៤៨០ (បួនរយប៉ែតសិប) គីឡូក្រាម ឡើងទៅ ។

៨- បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រាម ឡើងទៅ។

៩- សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី ១ ដល់ចំណុចទី ៨ នៃកថាខណ្ឌនេះ ។

**មាត្រា ៤១.. បទរឹបយកសារធាតុញៀន**

អំពើដោយចេតនាផ្លាស់ប្តូរដោយផ្ទុយច្បាប់នូវសារធាតុញៀន ដែលស្ថិតក្រោមការកាន់កាប់របស់អ្នកដទៃ មកដាក់ឲ្យស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន គឺជាអំពើរឹបយកសារធាតុញៀន ។

បទរឹបយកសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

ក្នុងករណីដែលការរឹបយកអាចកំណត់បានជាបទល្មើសផ្សេង ហើយបទល្មើសនេះត្រូវបានផ្តន្ទាទោសដែលអតិបរមានៃទោសដាក់ពន្ធនាគារ ធ្ងន់ជាងអតិបរមានៃទោសដាក់ពន្ធនាគារដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ ការរឹបយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដូចបទល្មើសផ្សេងនោះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ឧបសម្ព័ន្ធទី៥

44/5

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

សាលក្រមព្រហ្មទណ្ឌលេខៈ៤០៨ ក

ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៤៦

ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥

## ក្នុងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពត

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពត។

- បើកសវនាការៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ វេលាព្រឹក។
- ប្រកាសសាលក្រមៈ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦ វេលារសៀល។

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ឋានៈព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ ៥៤៦ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៥ ដែលមានជន

ជាប់ចោទៈ

ឈ្មោះ [redacted] ភេទប្រុស អាយុ ៦១ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ កើតនៅភូមិស្រែថ្កុង ឃុំបន្ទាយមាសខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត មានទីលំនៅនៅភូមិស្រែថ្កុង ឃុំបន្ទាយ មាសខាងជើង ស្រុក បន្ទាយមាស ខេត្តកំពត។ ឪពុកឈ្មោ [redacted] យឈ្មោះ [redacted] ាសពីមុនគ្មាន។ (បង្គាប់ឱ្យចាប់លេខ ១២៤ ចុះថ្ងៃទី ២៦.០៤.២០១៦)

ត្រូវបានជាប់ចោទពីបទៈ **ឃាតកម្ម** ប្រព្រឹត្តនៅភូមិស្រែថ្កុង ឃុំបន្ទាយ មាសខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី ៣០.០៥.២០១៦។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ។

ដែលមានលោ[redacted]មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៣៣៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត។

**<u>ដើមបណ្តឹងរដ្ឋប្បវេណី</u>**

ឈ្មោ[redacted]ភេទប្រុស អាយុ៦១ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីលំនៅបច្ចុប្បន្ននៅភូមិពន្លៃ ឃុំកំពេង ស្រុកគីរីវង់ ខេត្តកំពត ។

**ឯអង្គហេតុនៃរឿងមានដូចតទៅៈ**

កាលពីថ្ងៃទី ២១.០៩.២០១៥ វេលាម៉ោង ១៩ និង ៣០នាទី មានករណីឃាតកម្ម បានកើតឡើង នៅចំណុចភូមិស្រែថ្កុង ឃុំបន្ទាយ មាសខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត ដែលបង្កឡើងដោយឈ្មោ[redacted]នយកពូថៅកាប់ទៅលើ[redacted]នប្រសារបណ្តាលឱ្យស្លាប់នៅនឹងកន្លែង រួចហើយក៏បានរត់គេចខ្លួនបាត់។ មុនពេលកើតហេតុឈ្មោះ[redacted] បានមកពីដើរលេង ហើយទំនងជាស្រវឹងស្រាផង ពេលនោះឈ្មោះ[redacted]កូនរបស់ឈ្មោះ [redacted]បានសួររកទូរស័ព្ទដៃ ពេលនោះឈ្មោះ [redacted]បានឆ្លើយថា [redacted]ស័ព្ទទៅ[redacted]វិញទៅ បន្ទាប់មក[redacted]ស្រែកយំឡើងថា ទូរស័ព្ទបានលុបបទចំរៀង និងរឿងអស់ហើយ ក្រោយពីពូកូននិយាយ ឈ្មោ[redacted]ក៏បានស្រែកឡូឡាហើយ ថែមទាំងបោកផ្តិន និងជេរឈ្មោ[redacted] ដែលជាឪពុកក្មេក ដោយខឹងខ្លាំងពេកទើបឈ្មោះ [redacted] ជាឪពុកក្មេកបានយកពូថៅកាប់ទៅលើឈ្មោះ[redacted]ដែលជាកូនប្រសារបណ្តាលឱ្យស្លាប់នៅនឹងកន្លែង។

**នាពេលសវនាការ**

**ក្រោយពីបានៈ**

- ស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]
- ស្តាប់អំណានចម្លើយសាក្សីឈ្មោះ[redacted]
- ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

44/3

# សំអាងហេតុ

១-តាមរបាយការណ៍ស៊ើបអង្កេតសន្និដ្ឋាន ដោយមន្ត្រីនគរបាលយុត្តិធម៌ មានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់បានថា ពិតជាមានអំពើឃាតកម្ម កាលពីថ្ងៃទី ២១.០៩.២០១៥ នៅត្រង់ចំណុចភូមិស្រែថ្កុង ឃុំបន្ទាយ មាសខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត បង្ករឡើងដោយឈ្[redacted]យបានយកពូថៅកាប់ទៅលើជនរងគ្រោះ[redacted]កូនប្រសារ បណ្តាលឱ្យស្លាប់ ប្រាកដមែន។

២-ជនជាប់ចោទបានរត់គេចខ្លួនតាំងតែពីថ្ងៃប្រព្រឹត្តបទល្មើស។ *ការរត់គេចខ្លួនរបស់ជនជាប់ចោទសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ហើយរត់គេចខ្លួនដើម្បីឱ្យខ្លួនរួចផុតពីទំនួលខុសត្រូវផ្លូវច្បាប់តែប៉ុណ្ណោះ។*

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]ន [redacted] បានឆ្លើយប្រហាក់ប្រហែលគ្នាថា នៅថ្ងៃទី ២១.០៩.២០១៥ ម៉ោង ១៩ និង ៣០នាទី ខ្លួនបានឮសំលេងឈ្មោះ[redacted]ទូរស័ព្ទ ហើយពេលដែលវាបានទូរស័ព្ទហើយ វាស្រែកយំព្រោះទូរស័ព្ទរបស់វាបាត់ចំរៀង និងរឿងអស់។ ហើយឈ្មោ[redacted]ស្រែកថា កូនអញលេងមួយថ្ងៃហើយមិនអីផង ស្រាប់តែឮសំលេងគាត់បោកផ្ទិល ហើយស្រែកអូស។ ជួយផងឪក្មេកខ្លួនកាប់ខ្លួនហើយ។

៧-នាពេលសវនាការ លោកតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌, ចម្លើយបំភ្លឺរបស់សាក្សី និងការរត់គេចខ្លួនរបស់ជនជាប់ចោទ អាចឱ្យតំណាងអយ្យការសន្និដ្ឋានបានថា ជនជាប់ចោទឈ្[redacted]ិតជាបានយកពូថៅកាប់ជនរងគ្រោះឈ្មោ[redacted]ណ្តាលឱ្យស្លាប់នៅនឹងកន្លែង ប្រាកដមែន។ ហេតុដូច្នេះ តំណាងអយ្យការសុំតម្កល់បទចោទ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ១៩២ ចុះថ្ងៃទី ៣០.០៥.២០១៦ ទុកជាបានការទាំងមូលដដែល។ អយ្យការប្តឹងសុំឱ្យតុលាការពិនិត្យ និងសម្រេច តាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្តីសន្និដ្ឋានថាៈ ក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ សំណូមពរក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណា ធ្វើការកែប្រែបទចោទប្រកាន់មកត្រឹម បទល្មើសមនុស្សឃាតដោយអចេតនា ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងបន្ធូបន្ថយទោសដល់កូនក្តីខ្លួន ដោយមូលហេតុកូនក្តីខ្លួនជាមនុស្សចាស់ និងពុំធ្លាប់មានប្រវត្តិ ប្រព្រឹត្តអំពើហឹង្សា ឬធ្លាប់ប្រព្រឹត្តបទល្មើសណាមួយឡើយ។ លើសពីនេះទៅទៀត ដោយមូលហេតុស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមគ្រួសារគាត់ផ្ទាល់

*ការប្រព្រឹត្តរបស់ជនជាប់ចោទ គឺជាការប្រព្រឹត្តដោយចេតនា ដោយការយល់ដឹងច្បាប់ពីផលដែលនឹងកើតពីអំពើរបស់ខ្លួន។*

៣-ការរត់គេចខ្លួនរបស់ជនជាប់ចោទរបស់ជនជាប់ចោទ ស៊ីសង្វាក់ទៅនឹងចម្លើយរបស់សាក្សី និងសេចក្តីសន្និដ្ឋានរបស់មន្ត្រីនគរបាលយុត្តិធម៌ឃើញថា មានភាពគ្រប់គ្រាន់អាចឱ្យតុលាការជឿបានថាជនជាប់ចោទពិតជាបាន សម្លាប់ជនរងគ្រោះ នៅត្រង់ចំណុចភូមិស្រែថ្កុង ឃុំ បន្ទាយ មាសខាងជើង

ស្រុកបន្ទាយមាស ខេត្តកំពត។ អំពើនេះមានធាតុផ្សំជាបទ មនុស្សឃាតដោយចេតនា ក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

៣.១-ជនជាប់ចោទជានីតិជន ហើយបានប្រព្រឹត្តសកម្មភាពខាងលើ ដោយចេតនាយល់ដឹងគ្រប់គ្រាន់

៣.២-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ[redacted]ប្រព្រឹត្តនៅភូមិស្រែថ្កុង ឃុំបន្ទាយ មាសខាងជើង ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី ៣០.០៥.២០១៦។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រម ព្រហ្មទណ្ឌ ។

៣.៤-គប្បីប្រកាសទណ្ឌកម្មលើជនជាប់ចោទឈ្មោះ[redacted]យពិចារណាដល់ភាពធ្ងន់ស្រាល នៃសកម្មភាពល្មើស ផលប៉ះពាល់ និងព្យសនកម្ម ដែលកើតចេញពីអំពើល្មើស និងស្ថានភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ដូចខាងក្រោម:

-អំពើល្មើសរបស់ជនជាប់ចោទ ធ្វើឱ្យជនរងគ្រោះបាត់បង់ជីវិត ហើយជនជាប់ចោទប្រព្រឹត្តបទដោយភាពឃោរឃៅ ដែលទង្វើនោះធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់សាធារណៈ។ ម្យ៉ាងទៀត ជនជាប់ចោទ បានរត់គេចខ្លួនតាំងតែពីថ្ងៃប្រព្រឹត្តបទល្មើស តែការប្រព្រឹត្តនេះទើបតែលើកទីមួយ។ ទង្វើទាំងនេះហើយ ដែលនាំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទ ដូចក្នុងចំណុច ៣.៤ ។

៤-ជនជាប់ចោទឈ្មោះ[redacted]ត្រូវបានតុលាការសម្រេចផ្ដន្ទាទោស ១០ឆ្នាំ ដោយ គ្មានការព្យួរទោស ហើយជននេះបានរត់គេចខ្លួនក្រោយពេលប្រព្រឹត្តបទល្មើស និងមានភស្តុតាងគ្រប់គ្រាន់ ច្បាស់លាស់ថាជននេះពិតជាបានប្រព្រឹត្តបទល្មើសខាងលើ។ ហេតុនេះ គប្បីតុលាការចេញដីកាបង្គាប់ឱ្យ ចាប់ខ្លួនជននេះ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

៥-ឪពុករបស់ជនរងគ្រោះឈ្មោះ[redacted]តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណងជំងឺចិត្តចំនួន ២៤.០០០.០០០៛ (ម្ភៃបួនលានរៀល) ឃើញថា បណ្ដឹងនេះធ្វើឡើងមានលក្ខណៈ ត្រឹមត្រូវតាមមាត្រា ១៣, ១៤, ១៥, ២១ និង ២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការព្រហ្មទណ្ឌ អាចពិនិត្យនិងសម្រេចបាន តាមមាត្រា ២៣ និង៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តាមការពិនិត្យឃើញថា ការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីមានចំនួនច្រើន ដែលតុលាការគប្បីតុលាការបន្ធូបន្ថយមួយចំនួនធំ។

## សេចក្ដីសម្រេច

១-ផ្ដន្ទាទោសឈ្មោះ[redacted]ស អាយុ ៦១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្រែថ្កុង ឃុំបន្ទាយមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត អាសយដ្ឋានមុនពេលគេចខ្លួននៅភូមិស្រែថ្កុង ឃុំបន្ទាយមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត។ ឪពុកឈ្មោះ[redacted] ម្ដាយឈ្មោះ[redacted] មុខក្មាន។ (គេចខ្លួន)

**ដាក់ពន្ធនាគារកំណត់ចំនួន ១០ឆ្នាំ (ដប់ឆ្នាំ)។  ពីបទ ឃាតកម្ម។**

ប្រព្រឹត្តនៅភូមិស្រែថ្នុង ឃុំបន្ទាយ មាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត កាលពីថ្ងៃទី ២១.០៩.២០១៥។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ានសញ្ជាតិដូចខាងលើ និង យកមកឃុំខ្លួនក្នុងពន្ធនាគារ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យជនជាប់ចោទ [redacted] ំណងជម្ងឺចិត្តទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] *១០.០០០.០០០រៀល (ដប់លាន)*។ ការទាមទារ លើសពីនេះ បដិសេធចោល។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។ ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពត,ថ្ងៃទី..២០.....ខែ..មេសា..ឆ្នាំ2017

ក្រឡាបញ្ជី

[redacted]

ក្រឡាបញ្ជីលោក [redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តត្បូងឃ្មុំ

សំណុំរឿងព្រហ្មទណ្ឌលេខ: ១៨៧ ចុះ
ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥

សាលក្រម

លេខ ០៤ " គ " ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦

## គោរពនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តត្បូងឃ្មុំ

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តត្បូងឃ្មុំ នាថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយមានសមាសភាពដូចតទៅ:

<u>ចៅក្រមជំនុំជម្រះ</u>

-លោក [redacted] ចៅក្រមជំនុំជម្រះ ខេត្តត្បូងឃ្មុំ

<u>តំណាងអយ្យការ</u>

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តត្បូងឃ្មុំ

<u>ក្រឡាបញ្ជីសវនាការ</u>

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ

<u>មេធាវីការពារសិទ្ធិ</u>

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted] ឈ្មោះ[redacted] ហៅ[redacted]

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]និង ឈ្មោះ[redacted]ហៅ[redacted]ឈ្មោះ[redacted]ហៅ [redacted]និងឈ្មោះ[redacted]

<u>ដើម្បីជំនុំជំរះ</u>

លើសំណុំរឿងព្រហ្មទណ្ឌលេខ: ១៨៧ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ហៅ[redacted]ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិជ្រៃបិទមាស ឃុំសូង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ និងទីលំនៅមុនពេលចាប់ខ្លួននៅភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ[redacted] "ស" ប្រពន្ធឈ្មោះ[redacted]មានកូន០២នាក់ (កូន០១នាក់អាយុ៦ឆ្នាំ និង០១នាក់ទៀតអាយុ៤ឆ្នាំ ជាអនីតិជន) ប្រវត្តិ

នៃការផ្តន្ទាទោសដោយតុលាការ គ្មាន ចាប់ខ្លួនថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ និងឃុំខ្លួនថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

២-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកំពង់ទ្រាស ឃុំកំពង់ទ្រាស ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម និងទីលំនៅមុនពេលចាប់ខ្លួននៅភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ចាប់ខ្លួនថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ និងឃុំខ្លួនថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

៣-ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិដើមជ្រៃ ឃុំក្រូចឆ្មារ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម និងទីលំនៅមុនពេលចាប់ខ្លួននៅភូមិត្បូង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] គ្មានកូន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ចាប់ខ្លួនថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ និងឃុំខ្លួនថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

៤-ឈ្មោះ [redacted] ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី៩ ទីកន្លែងកំណើតនៅភូមិទួលខ្សាច់ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម និងទីលំនៅមុនពេលចាប់ខ្លួននៅភូមិចំការថ្មី ឃុំគគី ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ចាប់ខ្លួនថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ និងឃុំខ្លួនថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥។

៥-ឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិជ្រៃបិទមាស ឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម និងបច្ចុប្បន្ននៅភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសគ្មាន។

-ជនទាំង០៥នាក់ខាងលើនេះជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ឯរឿងហេតុកើតឡើងមានដូចតទៅ ៖

កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង១៥ និង៣០នាទី នៅចំណុចភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កំលាំងការិយាល័យប្រឆាំងគ្រឿងញៀន សហការជាមួយសមត្ថកិច្ចគ្រឿងញៀន ខេត្តត្បូងឃ្មុំ បានចុះបង្ក្រាបបទល្មើសគ្រឿងញៀន ដោយបានដឹកនាំដោយតំណាងអយ្យការអមសាលាដំបូង ខេត្តត្បូងឃ្មុំ [redacted] ឃើញមានថ្នាំញៀនប្រភេទម្សៅ ព៌ណសថ្លា,ថ្នាំគ្រាប់ប្រភេទ WY ឆែកឆេរនៅក្នុងផ្ទះរបស់ឈ្មោះ [redacted] ,ឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀន,ឧបករណ៍ចំនួន០២គ្រឿង,ឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀន,ឧបករណ៍ ចំនួន០៦គ្រាប់,ជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនចំនួន០២គ្រឿង,ឧបករណ៍សម្រាប់ប្រើប្រាស់ថ្នាំញៀន,ឧបករណ៍សម្រាប់វេចខ្ចប់ថ្នាំញៀនមួយចំនួន និងគ្រាប់កាំភ្លើងធុនវ៉ិឡូ ចំនួន១៤គ្រាប់ព្រមទាំងបានឃាត់ខ្លួនជនល្មើស

ឈ្មោះ [redacted] ហៅ [redacted] ,ឈ្មោះ [redacted] ,ឈ្មោះ [redacted] និងឈ្មោះ [redacted] បន្ទាប់មកសមត្ថកិច្ចប៉ូលិស បានបញ្ជូនជនល្មើសទាំងបួននាក់ និងកសាងសំណុំរឿងបញ្ជូនមកតុលាការ ដើម្បីចាត់ការតាមនីតិវិធី ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ១៨៧ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៤០ អ.យ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ របស់តំណាងរាជអាជ្ញាអមសាលាដំបូង ខេត្តត្បូងឃ្មុំ ។

-បានឃើញ ដីកាដំណោះស្រាយលេខ: ២៧៤/២០១៥ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ សាលាដំបូង ខេត្តត្បូងឃ្មុំ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះ លេខ: ៥៣ /២០១៥ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៥ របស់ប្រធានសាលាដំបូង ខេត្តត្បូងឃ្មុំ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] បានឆ្លើយថា: កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឈ្មោះ [redacted] បាននាំឈ្មោះ [redacted] និងឈ្មោះ [redacted] មកផ្ទះខ្លួន ដោយយកខ្លាយជ្រូកព្រៃមកលក់ឱ្យខ្លួនក្នុងតម្លៃ៣០០$ ពេលខ្លួនកំពុងពិនិត្យមើលខ្លាយជ្រូកព្រៃនោះ ឈ្មោះ [redacted] បានសុំចែកថ្នាំញៀនពីខ្លួន១០$ ហើយក៏ជក់នៅផ្ទះរបស់ខ្លួន ទាំងអស់គ្នា ពេលនោះខ្លួនក៏បានយកឧបករណ៍សម្រាប់ជក់គ្រឿងញៀនមក ពេលកំពុងជក់បានម្នាក់១ហឺត ស្រាប់តែមានសមត្ថកិច្ចប៉ូលីសមកដល់ចាប់ឃាត់ខ្លួននិងឈ្មោះ [redacted] ,ឈ្មោះ [redacted] និងឈ្មោះ [redacted] តែម្តង។ ចំពោះថ្នាំញៀនទាំងអស់ខ្លួនបានទិញពីឈ្មោះ [redacted] ដោយឈ្មោះ [redacted] បានផ្ញើថ្នាំញៀនតាមរថយន្តតាក់ស៊ី ហើយឈ្មោះ [redacted] នៅភូមិជ្រៃបិទមាស ជាអ្នកយកថ្នាំញៀនមកឱ្យខ្លួន។ កន្លងមកខ្លួនធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ [redacted] ចំនួន០៦ដង មកហើយ ដោយទិញថ្នាំញៀនម្តង១ពី២០០$ ទៅ៣០០$ ដើម្បីយកទៅលក់បន្ត។ ពេលសមត្ថកិច្ចឆែរឆេរ បានដកយកនូវប្រាក់ដុល្លាចំនួនប្រហែល២០០$ (ពីររយដុល្លា),ថ្នាំញៀនប្រភេទមេតាំហ្វេតាមីនចំនួន៥ជី ,ថ្នាំគ្រាប់ចំនួន០៤គ្រាប់ ,គ្រាប់កាំភ្លើងចំនួន១៤គ្រាប់ ទាំងនេះជារបស់ខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: ដំបូងឈ្មោះ [redacted] ហៅ [redacted] បានទូរស័ព្ទហៅខ្លួនឱ្យជូនភរទៅក្រុងសួង ដើម្បីយកខ្លាយជ្រូកព្រៃទៅលក់ឱ្យគេ ហើយខ្លួនក៏បានធ្វើដំណើរពីខេត្តក្រចេះ មកក្រុងសួង ជាមួយឈ្មោះ [redacted] បន្ទាប់មកខ្លួន និងឈ្មោះ [redacted] បានណាត់ជួបឈ្មោះ [redacted] ដើម្បីពិនិត្យមើលខ្លាយជ្រូកព្រៃ រួចហើយឈ្មោះ [redacted] ក៏បាននាំពួកខ្លួនទៅផ្ទះឈ្មោះ [redacted] ដោយយកខ្លាយជ្រូកព្រៃទៅលក់ឱ្យក្នុងតម្លៃ៣០០$ ពេលនោះឈ្មោះ [redacted] បានបបួលពួកខ្លួនជក់ថ្នាំ ហើយក៏បានរៀបចំសម្ភារៈសម្រាប់ជក់ថ្នាំញៀន តែមិនទាន់បានជក់ផង សមត្ថកិច្ចប៉ូលីសកក៏បានមកដល់ចាប់ឃាត់ពួកខ្លួនតែម្តង។

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា: កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ ខ្លួនបានទូរស័ព្ទទៅឈ្មោះ [redacted] ដើម្បីទាក់ទងយកខ្លាយជ្រូកព្រៃទៅលក់។ លុះបានបន្តិចខ្លួនបានទៅដល់ក្រុងសួងជួបឈ្មោះ [redacted] ហើយឈ្មោះ [redacted] បាននាំខ្លួនទៅជួបឈ្មោះ[redacted]ដើម្បីលក់ខ្លាយជ្រូកព្រៃ។ មកដល់ផ្ទះឈ្មោះ [redacted]ខ្លួនបានយកខ្លាយជ្រូកព្រៃឱ្យមើល ពេលឈ្មោះ [redacted] បានពិនិត្យមើល ស្រាប់តែមានក្មេងប្រុសម្នាក់មិនស្គាល់ឈ្មោះបានមកទិញថ្នាំញៀន ពីឈ្មោះ [redacted] ចំនួន០១កញ្ចប់ ហើយក៏ចុះទៅបាត់ទៅ។ ឃើញបែបនេះឈ្មោះ [redacted]បានទិញថ្នាំញៀនពីឈ្មោះ [redacted]ចំនួន១០$ ដើម្បីជក់នៅលើផ្ទះឈ្មោះ[redacted]ពេលដែលកំពុងជក់ថ្នាំ ស្រាប់តែសមត្ថកិច្ចមកដល់ចាប់ឃាត់ពួកខ្លួនតែម្តង។

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា: កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឈ្មោះ[redacted]ទូរស័ព្ទមកខ្លួនថាវាចង់លក់ខ្លាយជ្រូកព្រៃ ហើយខ្លួនក៏បានប្រាប់ឈ្មោះ[redacted]ឱ្យមកជួបខ្លួននៅក្រុងសួង ហើយវាឱ្យខ្លួនមកចាំវានៅបេនឡានក្រុងសួង បានមកដល់ឃើញឈ្មោះ[redacted]មកជាមួយឈ្មោះ [redacted] ហើយខ្លួនក៏បាននាំឈ្មោះ[redacted]និងឈ្មោះ[redacted]ទៅផ្ទះឈ្មោះ[redacted] ដោយយកខ្លាយជ្រូកព្រៃទៅលក់ឱ្យក្នុងតម្លៃ៣០០$ ពេលនោះមានគេមកទិញថ្នាំញៀនពីឈ្មោះ[redacted] តែទិញចំនួនប៉ុន្មានខ្លួនមិនបានដឹងទេ ហើយអ្នកទិញចេញមកនិយាយថាគ្រាន់តែសុំ១០,០០០៛ ចាក់សាំងមិនបាន បន្ទាប់មកឈ្មោះ[redacted]បានរៀបចំសម្ភារៈជក់ថ្នាំញៀន ពេលនោះខ្លួនបានចេញមកមាត់ទ្វារ ហើយឈ្មោះ[redacted]បានយកថ្នាំញៀន១កញ្ចប់តូចដាក់ក្នុងហោប៉ាវឱ្យខ្លួន បានបន្តិចខ្លួនឃើញ សមត្ថកិច្ចប៉ូលីសមកដល់ចាប់ឃាត់ពួកខ្លួនតែម្តង។

-ជនជាប់ចោទឈ្មោះ[redacted](អវត្តមាន) រត់គេចខ្លួន។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះឃើញថា: ជនជាប់ចោទឈ្មោះ[redacted]បានសារភាពថាខ្លួនជាអ្នកលក់ដូរថ្នាំញៀន ហើយថ្នាំញៀនទាំងអស់នេះជារបស់ខ្លួន ឯឈ្មោះ[redacted]ជាអ្នកយកថ្នាំមកឱ្យឈ្មោះ[redacted]ដូច្នេះតំណាងអយ្យការនៅតែចោទប្រកាន់លើឈ្មោះ[redacted]និងឈ្មោះ [redacted]ពីបទ: ជួញដូរគ្រឿងញៀន ដដែល។ ដោយឡែកឈ្មោះ[redacted],ឈ្មោះ[redacted]និងឈ្មោះ[redacted]បានសារភាពថា: ពួកខ្លួនមានគោលបំណងទៅផ្ទះឈ្មោះ [redacted] ដើម្បីទៅលក់ខ្លាយតាំជ្រូកព្រៃ ឱ្យឈ្មោះ[redacted] ហើយពុំទាន់លក់ទិញផង ក៏ត្រូវឈ្មោះ [redacted]បានរៀបចំឧបករណ៍បបួលអ្នកទាំងបីនេះជក់ថ្នាំញៀនបានម្នាក់១ហឺតក៏ត្រូវសមត្ថកិច្ចប៉ូលីសមកដល់ឃាត់ខ្លួនតែម្តង។ ដូច្នេះតំណាងអយ្យការសុំកែប្រែបទចោទលើឈ្មោះ [redacted] ឈ្មោះ [redacted]និងឈ្មោះ[redacted]ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនវិញ តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ហេតុដូច្នេះសូមលោកចៅក្រមពិចារណាផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។

-មេធាវីការពារសិទ្ធិបានធ្វើសេចក្តីសន្និដ្ឋានថា: នៅពេលសវនាការនេះឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ[redacted]ឈ្មោះ [redacted] និងឈ្មោះ[redacted]ពុំបានប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀនទេ គឺពួកគាត់ទាំងបីនាក់ គ្រាន់តែបានបំពេញបេសកកម្មនាំផ្លូវ ឱ្យទៅឈ្មោះ[redacted] ប៉ុណ្ណោះ។ ដោយពីមុនពួកគាត់ធ្លាប់ជក់ថ្នាំញៀន ក៏នាំគ្នាជក់ថ្នាំញៀនជាមួយឈ្មោះ [redacted] តែម្តងទៅ។ ហើយម្យ៉ាងទៀតតំណាងអយ្យការបានកែប្រែបទចោទលើកូនក្តីខ្លួនទាំងបីនាក់ អំពីបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយម៉ែរ ហេតុដូច្នេះសូមលោកចៅក្រមឱ្យកូនក្តីខ្លួនទាំងបីនាក់រួចខ្លួនពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកត្រឹមតែបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងសុំឱ្យសម្រាលទោសដល់អ្នកទាំងបីនាក់នេះផង។

-ជនជាប់ចោទឈ្មោះ[redacted] ហៅ [redacted]និយាយសំដីចុងក្រោយថា: សូមឱ្យតុលាការសម្រាលទោសដល់ខ្លួន ពីព្រោះខ្លួនមានកូនតូចៗ និងមានឪពុកចាស់ជរាទៀតផង។

-ជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ[redacted]និយាយសំដីចុងក្រោយប្រហាក់ប្រហែលគ្នាថា: សូមឱ្យតុលាការសម្រាលទោសដល់ខ្លួន ខ្លួនរាងចាលហើយ។លែងប្រព្រឹត្តទៀតហើយ។

-ជនជាប់ចោទឈ្មោះ [redacted]និយាយសំដីចុងក្រោយថា: សូមឱ្យតុលាការសម្រាលទោសដល់ខ្លួន ពីព្រោះប្រពន្ធរបស់ខ្លួនមានផ្ទៃពោះ។

-បានឃើញ កំណត់ហេតុចូលវត្ថុតាង ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលមានម្សៅក្រាមពណ៌សចំនួន០៨កញ្ចប់ មានទម្ងន់២១,៧២,ប្រភេទថ្នាំគ្រាប់មានអក្សរWYចំនួន០៦គ្រាប់ មានទម្ងន់០,៦៥ក្រាម , គ្រាប់កាំភ្លើងធុន រ៉ូឡូ ចំនួន១៤គ្រាប់,ជញ្ជីងអេឡិចត្រូនិចចំនួន០២គ្រឿង និងឧបករណ៍ជក់មួយចំនួន។

-បានឃើញ ដីកាសម្រេចបញ្ជូនបណ្តឹងអាជ្ញាលេខ: ១៤៣ ព្រទ១,លេខ:១៤៤ ព្រទ១ ,លេខ: ១៤៥ ព្រទ១ និងលេខ: ១៤៦ ព្រទ១ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ លើឈ្មោះ[redacted]ឈ្មោះ:[redacted],ឈ្មោះ:[redacted]និងឈ្មោះ[redacted]

-បានឃើញ ដីកាបង្គាប់ឱ្យបញ្ជូនលេខ:១១៧/២០១៥,លេខ:១១៨/២០១៥ ,លេខ: ១១៩/២០១៥ និងលេខ: ១២០/២០១៥ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ លើឈ្មោះ: [redacted]ឈ្មោះ[redacted]ឈ្មោះ: [redacted] និងឈ្មោះ[redacted]

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារត្រឹមត្រូវហើយ

<u>សំអាងហេតុ</u>

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ានបញ្ជាក់ថា: កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឈ្មោ [redacted] បាននាំឈ្មោះ [redacted] និងឈ្មោះ [redacted] មកផ្ទះខ្លួន ដោយយកម្ញាយជ្រូកព្រៃមកលក់ឱ្យខ្លួនក្នុងតម្លៃ៣០០$ ពេលខ្លួនកំពុងពិនិត្យមើលម្ញាយជ្រូកព្រៃនោះ ឈ្មោ [redacted] បានសុំចែកថ្នាំញៀនពីខ្លួន១០$ ជក់នៅផ្ទះរបស់ខ្លួន ពេលនោះខ្លួនក៏បានយកឧបករណ៍សម្រាប់ជក់គ្រឿងញៀនមក ស្រាប់តែមានសមត្ថកិច្ចប៉ូលីសមកចាប់ឃាត់ខ្លួន និងឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] តែម្តង។ ចំពោះថ្នាំញៀនទាំងអស់ខ្លួនបានទិញពីឈ្មោះ [redacted] ដោយឈ្មោ [redacted] បានផ្ញើថ្នាំញៀនតាមរថយន្តតាក់ស៊ី ហើយឈ្មោះ [redacted] នៅភូមិជ្រៃបិទមាស ជាអ្នកយកថ្នាំញៀនមកឱ្យខ្លួន។ កន្លងមកខ្លួនធ្លាប់បានទិញថ្នាំញៀនពីឈ្មោ [redacted] ចំនួន០៦ដងមកហើយ ដោយទិញថ្នាំញៀនម្តង១ពី២០០$ ទៅ៣០០$ ដើម្បីយកទៅលក់បន្ត។ ចម្លើយទាំងនេះស្របនឹងភស្តុតាង និងរបាយការណ៍ពោធា របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឱ្យតុលាការពិចារណាបាន។

-តាមចម្លើយជនជាប់ចោទឈ្មោ [redacted] ,ឈ្មោះ [redacted] និងឈ្មោះ [redacted] បានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា: កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឈ្មោ [redacted] បាននាំឈ្មោះ [redacted] និងឈ្មោះ [redacted] បាននាំគ្នាទៅផ្ទះឈ្មោះ [redacted] ដោយយកម្ញាយជ្រូកព្រៃទៅលក់ឱ្យ ក្នុងតម្លៃ ៣០០$ ពេលនោះឈ្មោ [redacted] ានសុំចែកថ្នាំញៀនពីខ្លួន១០$ ពីឈ្មោះ [redacted] ហើយជក់នៅផ្ទះនោះ បន្ទាប់មកឈ្មោះ [redacted] ក៏បានយកឧបករណ៍សម្រាប់ជក់ថ្នាំញៀនមក តែមិនទាន់បានជក់ផង ស្រាប់តែមានសមត្ថកិច្ចប៉ូលីសមកចាប់ឃាត់ពួកខ្លួនតែម្តង។ ចម្លើយទាំងនេះស៊ីសង្វាក់ជាមួយភស្តុតាង និងរបាយការណ៍នានា របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឱ្យតុលាការពិចារណាបាន។

-តាមការពិនិត្យលើវត្ថុតាង ដកហូតពីឈ្មោះ [redacted] ឃើញម្សៅក្រាម ពណ៌សចំនួន០៨កញ្ចប់តូច,ថ្នាំគ្រាប់ចំនួន០៦គ្រាប់ ដញ្ញឹងសម្រាប់ថ្លឹងថ្នាំញៀនចំនួន០២ និងឧបករណ៍ជក់មួយចំនួន។ រីឯឈ្មោះ [redacted] ឈ្មោ [redacted] និងឈ្មោ [redacted] ត្រូវបានដកហូតអ្វីទេ។

-ដោយឆ្លងតាមការពិនិត្យភស្តុតាង,ចម្លើយជនជាប់ចោទ និងកាលៈទេសៈមធ្យោបាយប្រព្រឹត្តរបស់ជនល្មើស អាចបញ្ជាក់បានថា: កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង១៥,៣០នាទី នៅចំណុចភូមិជ្រៃបិទមាស សង្កាត់ស្នួង ក្រុងសួង ខេត្តត្បូងឃ្មុំ ឈ្មោះ [redacted] ងឈ្មោ [redacted] តជាបានប្រព្រឹត្តនូវអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើនេះជាបទល្មើស មានចែងក្នុងមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ឯជនជាប់ចោទឈ្មោះ [redacted] ,ឈ្មោះ [redacted] និងឈ្មោះ [redacted] ានប្រព្រឹត្តនូវអំពើប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើនេះមានចែងក្នុងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យចៅក្រមជំនុំជម្រះ កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសុំឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ការប្តឹងសុំនេះមានលក្ខណៈសមហេតុផល គប្បីទទួលពិចារណា និងសម្រេចតាមការស្នើសុំ។

-ជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ជានីតិជន មានស្មារតីនៅល្អ,ដឹងខុសត្រូវ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួន ចំពោះមុខច្បាប់។

-មានភស្តុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានភស្តុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted],ឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ: ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មេធាវីការពារសិទ្ធិជនជាប់ចោទក៏ដូចជនជាប់ចោទស្នើសុំឱ្យតុលាការពិចារណាសម្រាលទោសដល់ជនជាប់ចោទ ការស្នើសុំនេះតុលាការទទួលពិចារណា។

-ចំពោះវត្ថុតាងមានថ្នាំញៀនប្រភេទម្សៅក្រាមព៌ណស ចំនួន០៨កញ្ចប់,ប្រភេទថ្នាំគ្រាប់មានអក្សរ WY ចំនួន០៦គ្រាប់ ,គ្រាប់កាំភ្លើងធុនវ៉ូឡូចំនួន១៤គ្រាប់,ជញ្ជីងអេឡិចត្រូនិចចំនួន០២គ្រឿង និងឧបករណ៍ជក់មួយចំនួន ត្រូវរឹបអូសបំផ្លាញចោល។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសលើ៖

១-១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ។

១-២-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ។

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗរយៈពេល០២ឆ្នាំ(ពីរឆ្នាំ) ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុ

ញៀន ប្រព្រឹត្តនៅភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៥

តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

២-កែប្រែបទចោទលើជនជាប់ចោទឈ្មោះ[redacted]ឈ្មោះ[redacted]និងឈ្មោ[redacted]

បទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់

ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន មកបទៈ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤៥

កថាខណ្ឌ១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន វិញ។

៣-ផ្ដន្ទាទោសជនជាប់ចោទ

៣-១-ឈ្មោះ[redacted]ហៅ [redacted]ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ

៣-២-ឈ្មោះ [redacted]ហៅ [redacted]ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ

៣-៣-ឈ្មោះ[redacted]ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗរយៈពេល០៣ខែ១០ថ្ងៃ (បីខែ១០ថ្ងៃ) ពីបទៈ ប្រើប្រាស់ដោយខុស

ច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិជ្រៃបិទមាស សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០២ ខែវិច្ឆិកា

ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា៤៥ កថាខណ្ឌ១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៤-វត្ថុតាងរួមមាន ៖ ថ្នាំញៀនប្រភេទម្សៅក្រាមពណ៌ស ចំនួន០៨កញ្ចប់,ប្រភេទថ្នាំគ្រាប់មានអក្សរ

WY ចំនួន០៦គ្រាប់ ,គ្រាប់កាំភ្លើងធុនរ៉ូឡូចំនួន១៤គ្រាប់,ជញ្ជីងអេឡិចត្រូនិចចំនួន០២គ្រឿង និងឧបករណ៍ជក់

មួយចំនួន ត្រូវរឹបអូសបំផ្លាញចោល។

៥-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣

ខែកុម្ភៈ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]ឈ្មោះ[redacted]ឈ្មោះ[redacted]ឈ្មោះ

[redacted]និងកំបាំងមុខជនជាប់ចោទឈ្មោះ[redacted]សម្រេចបើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់

ច្បាប់។

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា

លោក[redacted]

ក្រឡាបញ្ជីសវនាការ

ហត្ថលេខា និងត្រា

លោក[redacted]

---

បានឃើញ

ធ្វើនៅថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៦

ចៅក្រមជំនុំជម្រះ

បានសម្រង់ត្រឹមត្រូវតាមច្បាប់ដើម

ត្បូងឃ្មុំ, ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៦

ក្រឡាបញ្ជី